ក្រសួងកិច្ចការនារី

សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ៧




# អំពើហិង្សា

## អំពើហិង្សាលើស្ត្រី និងក្មេងស្រី

### ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

**នី ផល្លា (២៣ឆ្នាំ)** បម្រើការជាប៉ូលីសជាង២ឆ្នាំមកហើយ ដោយសារនាងចង់ឱ្យសហគមន៍របស់នាងមានសុវត្ថិភាព ។ នាងសម្រេចចិត្តធ្វើជាប៉ូលីស ដោយសារឪពុករបស់នាងក៏ជាប៉ូលីសដែរ ។

# ជំពូកទី ៧

# អំពើហិង្សា

## អំពើហិង្សាលើស្ត្រី និងក្មេងស្រី

### បរិបទគោលនយោបាយ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានការពារសិទ្ធិរស់រានមានជីវិត សេរីភាព និងសុវត្ថិភាពដល់ប្រជាពលរដ្ឋ (មាត្រា៣២) និងធានាមិនឱ្យមានការបំពានលើរាងកាយបុគ្គល (មាត្រា៣៨)។

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានបង្កើតឡើង និងតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវ ក្នុងការអន្តរាគមន៍ក្នុងករណីមានអំពើហិង្សាកើតឡើង និងផ្តល់ដីកាការពារដែលចេញដោយតុលាការសម្រាប់ការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។

ការបៀតបៀនផ្លូវភេទ និងឥរិយាបទមិនសមរម្យនៅកន្លែងធ្វើការ ត្រូវបានហាមឃាត់តាមមាត្រា១៧២នៃច្បាប់ការងារព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បង្កើតឡើងដើម្បីប្រឆាំងនឹងការចាប់ជំរិតមនុស្ស ឬការកេងប្រវ័ញ្ចផ្លូវភេទ និងកំលាំងពលកម្ម។

គោលនយោបាយភូមិឃុំមានសុវត្ថិភាពបានកំណត់អំពើរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្សថាជាវិស័យអាទិភាពសម្រាប់ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង និងក្រុមប្រឹក្សាខេត្ត ដើម្បីអនុវត្ត។



▲ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារសម្រាប់ការពារជនរងគ្រោះនៃអំពើហិង្សាលើស្ត្រី

ក្រមរដ្ឋប្បវេណី ត្រូវបានរៀបចំឡើងនៅឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី នៅឆ្នាំ២០០៦ ក្រមព្រហ្មទណ្ឌ នៅឆ្នាំ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌ នៅឆ្នាំ២០០៧។

ច្បាប់ស្តីពីការគ្រប់គ្រងទឹកអាស៊ីត ត្រូវរៀបចំឡើងនៅឆ្នាំ២០១១។

ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២ ត្រូវបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត។

ផែនការសកម្មភាពជាតិបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ លើកទី២ កំពុងត្រូវបានរៀបចំ។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅឆ្នាំ១៩៩២ និងពិធីសារតាមជម្រើស នៅឆ្នាំ២០១០។

នៅឆ្នាំ១៩៩២ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ និងពិធីសារតាមជម្រើសដែលកំណត់នូវសិទ្ធិមនុស្សជាមូលដ្ឋានដែលក្មេងប្រុស និងក្មេងស្រីទទួលបាន រួមមានសិទ្ធិនៃការការពាររាល់ទម្រង់នៃអំពើហិង្សាលើរាងកាយ និងផ្លូវចិត្ត ការវាយដំ ឬការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ការធ្វើបាបឬការកេងប្រវ័ញ្ច រួមទាំងការបៀតបៀនភេទ (មាត្រា១៩)។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិជនពិការ (UNCRPD) ដែលក្នុងនោះមាត្រា៦ បានបញ្ជាក់អំពីការការពារដល់ស្ត្រីពិការ ក្នុងការឆ្លើយតបទៅនឹងការរើសអើង និងមាត្រ១៦ បញ្ជាក់អំពីសិទ្ធិ និងសេរីភាពរួចផុតពីការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពានផ្សេងៗ។

កម្ពុជាបានគាំទ្រដល់សេចក្តីថ្លែងការអន្តរជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច(UNDRIP)។ មាត្រា២២.២ បានបញ្ជាក់ថា រាល់វិធានការផ្សេងៗគួរធ្វើឡើងស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ដើម្បីធានាថា ស្ត្រីជនជាតិដើមភាគតិចទទួលនិងធានាបាននូវកិច្ចការពារលើរាល់ទម្រង់នៃអំពើហិង្សា និងការរើសអើងលើនារីភេទ។

លើសពីនេះ ក្នុងនាមរដ្ឋភាគីរបស់អង្គការសហប្រជាជាតិ កម្ពុជាបានសន្យាថានឹងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាពិសេសទាក់ទងនឹងស្ត្រី សន្តិភាព និងសន្តិសុខ តាមសេចក្តីសម្រេចលេខ (SCR) ១៣២៥ ១៨២០ និង១៨៨៨។

## របកគំហើញ

### ទប់ស្កាត់និងកាត់បន្ថយអំពើហិង្សាលើស្ត្រី៖ អំពើហិង្សាគឺជាការរំលោភសិទ្ធិមនុស្ស និងជាឧបសគ្គដល់ការអភិវឌ្ឍន៍

*ប្រេវ៉ាឡង់ នៃអំពើហិង្សាក្នុងគ្រួសារ[1] នៅតែមានកម្រិតខ្ពស់ នៅក្នុងប្រទេសកម្ពុជា*

- មានការអះអាងថា អំពើហិង្សាក្នុងគ្រួសាររវាងប្តីនិងប្រពន្ធ[2]មានការថយចុះ។

[1] អំពើហិង្សាក្នុងគ្រួសារដូចមានចែងក្នុងច្បាប់កម្ពុជាថា ជាអំពើហិង្សាដែលកើតឡើងរវាងប្តីឬប្រពន្ធ កូនក្នុងបន្ទុកឬមនុស្សដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងអ្នកដែលនៅក្នុងបន្ទុកគ្រួសារ។ អំពើហិង្សានេះ រួមមានអំពើហិង្សាផ្លូវភេទ ផ្លូវកាយ ផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច និងការបំពានផ្សេងៗនៅក្នុងផ្ទះ។

[2] នៅក្នុងការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា និងឯកសារអង្កេតតាមដានអំពើហិង្សាលើស្ត្រីរបស់ក្រសួងកិច្ចការនារី បានចាត់វិធានការ តែលើអំពើហិង្សារវាងប្តីនិង ប្រពន្ធ។

ទោះជាយ៉ាងនេះក្តីបើធៀបជាមួយទម្រង់នៃអំពើហិង្សាផ្សេងទៀត អំពើហិង្សាក្នុងគ្រួសារនៅតែមានកម្រិតខ្ពស់។ ទិន្នន័យថ្មីតម្រូវឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីប្រេវ៉ាឡង់ថ្មីៗ។ ទិន្នន័យនេះកំពុងចាប់ផ្តើមបង្ហាញឱ្យឃើញការកើនឡើងនូវហានិភ័យនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ។

តារាងទី១៖ ទិន្នន័យប្រេវ៉ាឡង់អំពើហិង្សាក្នុងគ្រួសារ រវាងប្តី និងប្រពន្ធ

| ការសិក្សា | អំពើហិង្សាលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត រវាងប្តី និងប្រពន្ធ | អំពើហិង្សា លើរាងកាយ រវាងប្តី និងប្រពន្ធ | អំពើហិង្សា ផ្លូវភេទ រវាងប្តី និងប្រពន្ធ |
|---|---|---|---|
| អង្កេតប្រជាសាស្ត្រ និង សុខភាព កម្ពុជាឆ្នាំ២០០០ | ២៥% | ១៦% | ៤% |
| កិច្ចការនារីឆ្នាំ២០០៤ | | ២២៥,% | - |
| អង្កេត ប្រជាសាស្ត្រ និង សុខភាព កម្ពុជា ឆ្នាំ២០០៥ | ២២,៣% | ១៣,៧% | ៣% |

- យោងតាមអង្កេតប្រជាសាស្ត្រ និងសុខភាព កម្ពុជាឆ្នាំ២០០៥ (ទិន្នន័យថ្មីបំផុត) បានបង្ហាញថា ស្ត្រី ធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទ និងផ្លូវចិត្តពីដៃគូរបស់គេមានការថយចុះពី២៥ភាគរយ ក្នុងឆ្នាំ២០០០ មកត្រឹម២២ភាគរយ ក្នុងឆ្នាំ២០០៥ (តារាងទី១)[3]។

- ឯកសារអង្កេតតាមដានអំពើហិង្សាលើស្ត្រីរបស់ក្រសួងកិច្ចការនារីបានបង្ហាញថា ជនរងគ្រោះបានរាយការណ៍ថា មានការថយចុះ នៃកម្រិតអំពើហិង្សាក្នុងគ្រួសាររវាងប្តី និងប្រពន្ធក្នុងគ្រប់ទម្រង់នៃអំពើហិង្សា (តារាងទី២)[4]។

- កម្មវិធីដៃគូដើម្បីការទប់ស្កាត់ បានធ្វើការសិក្សាអំពីបុរសដែលបានប្រើអំពើហិង្សាលើស្ត្រី ដោយធ្វើសម្ភាសន៍ស្ត្រីចំនួន៤១៧នាក់។ ក្នុងចំណោមស្ត្រីទាំងនោះមាន

[3] NIS. CDHS. Phnom Penh: Ministry of Planning, 2010.

[4] MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

២២ភាគរយ ធ្លាប់ទទួលរងគ្រោះដោយអំពើហិង្សាលើរាងកាយកាលពីឆ្នាំកន្លងមក និង២៥ភាគរយធ្លាប់ទទួលរងគ្រោះដោយអំពើហិង្សាលើរាងកាយ និងផ្លូវភេទក្នុងជីវិតរបស់ពួកគេ[5] ។

- នៅឆ្នាំ២០១៣ កម្មវិធីដៃគូដើម្បីការទប់ស្កាត់ បានធ្វើការសិក្សាដោយធ្វើការសម្ភាសន៍ជាមួយក្រុមបុរស និងស្ត្រីចំនួន១.៨៣១ នាក់ ពីបញ្ហាបុរសដែលបានប្រើអំពើហិង្សាលើស្ត្រីដោយបានរកឃើញថា បុរស ៣២,៥ភាគរយ បានប្រើអំពើហិង្សាលើរាងកាយ និងផ្លូវភេទលើដៃគូជិតស្និទ្ធរបស់ពួកគេ[6] ។
- ការសិក្សាអំពីអំពើហិង្សាលើកុមារនៅកម្ពុជា បានបង្ហាញថា ៥០ភាគរយទាំងប្រុសនិងស្ត្រី ធ្លាប់ទទួលរងគ្រោះដោយអំពើហិង្សាលើរាងកាយយ៉ាងតិចណាស់ម្តងក្នុងគ្រួសាររបស់ពួកគេ តាំងពីមុនអាយុ១៨ឆ្នាំ[7] ។
- ការសិក្សាស្រាវជ្រាវរបស់ Triple Jeopardyបានបង្ហាញថា ស្ត្រីពិការធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយពីដៃគូជិតស្និទ្ធរបស់ខ្លួនដូចស្ត្រីដែលមិនពិការដែរ។ ទោះដូចនេះក្តី ពួកគេទំនងជាទទួលរងនូវអំពើហិង្សាលើរាងកាយច្រើនជាងពីសមាជិកគ្រួសារដទៃទៀត។ ២៥ភាគរយនៃស្ត្រីពិការធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយពីសមាជិកគ្រួសារភាពនឹង១១,៤ភាគរយ នៃស្ត្រីដែលមិនពិការ[8]។
- ទិន្នន័យឃុំ សង្កាត់ទូទាំងប្រទេស បានធ្វើការកត់ត្រាចំនួនគ្រួសារ[9] រងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដែលបានស្វែងរកការជួយអន្តរាគមន៍ពីអាជ្ញាធរដែនដី។ នៅចន្លោះឆ្នាំ២០០៦ដល់ឆ្នាំ២០១០ ចំនួនគ្រួសារដែលរងគ្រោះដោយសារអំពើហិង្សា ក្នុងគ្រួសារបានថយចុះពី១,៦៣ភាគរយ មកត្រឹម ០,៨៨ភាគរយ ក្នុងឆ្នាំ២០១០។ ទិន្នន័យនេះមិនបានបញ្ជាក់ថា អំពើហិង្សា ឬការស្វែងរកការជួយអន្តរាគមន៍ពីអាជ្ញាធរដែនដី មានការថយចុះនោះទេ[10]។

---

5 Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

6 Ibid.

7 DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

8 Astbury, Jill and Fareen Walji. *Triple Jeopardy: Gender-based violence and human rights violations experienced by women with disabilities in Cambodia.* Phnom Penh: AUSAID, 2013.

9 របាយការណ៍ទិន្នន័យភូមិ/ឃុំ គ្រួសារ គឺមិនមែនបុគ្គល មិនបែកបាក់គ្នាដោយប្រភេទនៃហិង្សា ជនល្មើស ឬជនរងគ្រោះ

10 CDB Online. 2013. http://db.ncdd.gov.kh/cdbonline/home/index.castle ( accessed November, December 2013 ).



## មានការរាយការណ៍ថា អត្រារំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ មានកម្រិតខ្ពស់ ទាំងនៅក្នុងគ្រួសារ និងកន្លែងផ្សេងទៀត

▲ កិច្ចខំប្រឹងប្រែងត្រូវបានកំពុងធ្វើឡើង ដើម្បីជាការឆ្លើយតបក្នុងការទប់ស្កាត់ នៃអំពើហិង្សាលើស្ត្រី និងកុមារឱ្យកាន់តែប្រសើរឡើង

តារាងទី២៖ «តើប្ដីឬប្រពន្ធរបស់អ្នកធ្លាប់ប្រព្រឹត្តអំពើហិង្សាដែរទេ?»

ការប្រៀបធៀបអំពើហិង្សាដែលប្ដីឬប្រពន្ធធ្លាប់ទទួលរងតាមរយៈ ការសិក្សាទិន្នន័យដើមគ្រាស្ដីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឆ្នាំ២០០៥ និងអង្កេតតាមដានស្ដីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឆ្នាំ២០០៩

| ប្រភេទនៃអំពើហិង្សា | ទិន្នន័យដើមគ្រា ២០០៥ | ការអង្កេតតាមដាន ២០០៩ | ការថយចុះពីឆ្នាំ២០០៥មកឆ្នាំ២០០៩ |
|---|---|---|---|
| ស្រែកគំហក | ៧៥% | ៧៥% | ០% |
| ប្រទេចផ្ដាសសា | ៤៤% | ៣១% | ២៩,៥% |

| | | | |
|---|---|---|---|
| គ្រវែង (គប់) | ១៨% | ៦% | ៦៦,៧% |
| ខោកក្បាល | ១២% | ៤% | ៦៦,៧% |
| ចង ឬវាយ | ៤% | ១% | ៧៥% |
| គំរាមកំហែងដោយកាំបិត | ៥% | ១% | ៨០% |
| ដុត ឬអុជ | ១% | ០% | ១០០% |
| ជះទឹកអាស៊ីត | ១% | ០% | ១០០% |

*ប្រភព៖ របាយការណ៍អង្កេត តាមដានស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឆ្នាំ២០០៩*

- ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទត្រូវបានប្រព្រឹត្តឡើងដោយសមាជិកគ្រួសារ អ្នកដែលស្គាល់គ្នា និងជួនកាលជនដែលមិនស្គាល់។ ការប្រព្រឹត្តអាចកើតឡើងនៅក្នុងផ្ទះ សាលារៀន កន្លែងធ្វើការ និងនៅក្នុងសហគមន៍។ ការសិក្សាស្រាវជ្រាវនៅកម្ពុជានៅមានកម្រិត ប៉ុន្តែមានទិន្នន័យជាក់លាក់ដែលរាយការណ៍ដោយជនរងគ្រោះពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ។ ការរំលោភសេពសន្ថវៈ គឺជាប្រភេទដែលត្រូវបានគេរាយការណ៍ថាជាបទល្មើសឧក្រិដ្ឋ។

- ការសិក្សាអំពីអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣ បានរកឃើញថា ៤ភាគរយនៃស្ត្រី និង៥ភាគរយនៃបុរស ដែលមានអាយុចន្លោះពី១៨ឆ្នាំទៅ២៤ឆ្នាំ បានរាយការណ៍ថា បានទទួលការរំលោភផ្លូវភេទយ៉ាងតិចម្តងមុនអាយុ១៨ឆ្នាំ។ ជនល្មើសប្រព្រឹត្តអំពើរំលោភផ្លូវភេទលើកុមារដែលជារឿយៗត្រូវបានស្គាល់ថា ជាអ្នកជិតខាង ជាមិត្តភ័ក្ត មិត្តប្រុស ឬជាសមាជិកគ្រួសារនៃជនល្មើសដែលប្រព្រឹត្តអំពើរំលោភផ្លូវភេទលើកដំបូង[11]។

- ការសិក្សាអំពីអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣ បានរកឃើញថា ២៤ភាគរយនៃស្ត្រី និង៩ភាគរយនៃបុរសដែលមានអាយុចន្លោះពី១៨ឆ្នាំ ទៅ២៤ឆ្នាំ បានរាយការណ៍ថា ការរំលោភផ្លូវភេទលើកដំបូងមិនមានការយល់ព្រម[12]។

[11] DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

[12] Ibid.

- តាមការសិក្សារបស់កម្មវិធីដៃគូដើម្បីការទប់ស្កាត់ ជាមួយស្ត្រីធ្លាប់មានដៃគូចំនួន ៤១៧នាក់បាន រកឃើញថា ស្ត្រីម្នាក់ក្នុងចំណោម១០នាក់ បានរាយការណ៍ថាធ្លាប់ទទួលរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ឬការចាប់រំលោភពីដៃគូរបស់ខ្លួនក្នុងពេលរស់នៅជាមួយគ្នា[13]។

- តាមការសិក្សារបស់កម្មវិធីដៃគូដើម្បីការទប់ស្កាត់ ១ក្នុងចំណោម៥នៃដៃគូស្និទ្ធស្នាល បុរសជាអ្នកប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ។ ការសិក្សានេះបានរកឃើញថា ការរំលោភសេពសន្ថវៈ ជាធម្មតាភាគច្រើនធ្វើទៅលើដៃគូស្និទ្ធស្នាលដោយ ២០,៨ភាគរយនៃដៃគូជាបុរសបានរាយការណ៍ថា មានការរំលោភទៅលើដៃគូរបស់ខ្លួន ហើយ៨,៣ភាគរយនៃការសម្ភាសន៍ជាមួយបុរស បានរាយការណ៍ថាពួកគេបានចាប់រំលោភសេពសន្ថវៈលើស្ត្រី ឬក្មេងស្រីដែលមិនមែនជាដៃគូរបស់ពួកគេ[14]។

- ជាងពាក់កណ្តាលនៃបុរសជាក្រុមចាប់រំលោភសេពន្ថវៈគឺជាយុវជន ហើយពួកគេទើបតែប្រព្រឹត្តជាលើកទី១។ ១៦ភាគរយ នៃយុវជនទាំងនេះបានប្រព្រឹត្តអំពើរំលោភសេពន្ថវៈមុនអាយុ១៥ឆ្នាំ និងមានម្នាក់ក្នុងចំណោម១០នាក់បានប្រព្រឹត្តអំពើចាប់រំលោភសេពសន្ថវៈ៤ដងឬច្រើនជាងនេះ[15]។

- ការរំលោភសេពសន្ថវៈនៃក្រុមក្មេងស្ទាវ ករណីរំលោភបូក ជាញឹកញាប់ធ្វើឡើងទៅលើអ្នករកស៊ីផ្លូវភេទដែលគេទទួលស្គាល់ជាទូទៅថា ជាសកម្មភាពរួមភេទសម្រាប់ការសប្បាយនៃក្រុមយុវជន ជាពិសេសនៅតំបន់ជាយក្រុង។ តាមការរកឃើញរបស់ P4P ៨,៣ភាគរយនៃបុរសជាអ្នកចាប់រំលោភសេពសន្ថវៈបានធ្វើទៅលើអ្នកមិនមែនជាដៃគូ។ ៥,២ភាគរយ ជាអ្នកប្រព្រឹត្តបទល្មើសរំលោភជាក្រុម ឬបទល្មើសរំលោភបូក។ របាយការណ៍បានបង្ហាញថា ស្ថិតិនេះគឺមានអត្រាខ្ពស់និងគួរឱ្យបារម្ភ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសដទៃទៀតក្នុងតំបន់[16]។

---

[13] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

[14] Ibid.

[15] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

[16] Ibid.

- ការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាលើកុមារនៅកម្ពុជា បានរកឃើញថាការរំលោភផ្លូវភេទដោយជនល្មើស ច្រើនជាងម្នាក់ មិនមែនជារឿងចំឡែកទេ[17]។ ជនល្មើសភាគច្រើនដែលមានអាយុចន្លោះពី ១៨ឆ្នាំ ដល់២៤ឆ្នាំក្នុងនោះស្ត្រី១នាក់ក្នុងចំណោម ១០នាក់ និង បុរស១ភាគ៤មានជាប់ទាក់ទងទៅនឹងឧប្បត្តិហេតុដំបូងនៃការរំលោភបំពានផ្លូវភេទលើកុមារ។ ក្រុមយុវជនអាយុចន្លោះពី១៣ឆ្នាំដល់១៧ឆ្នាំ មានស្ត្រី ១នាក់ក្នុងចំណោមស្រី៨នាក់ និងបុរស១នាក់ក្នុងចំណោមបុរស៦នាក់បានរាយការណ៍ថា ជនល្មើសមួយចំនួនបានប្រព្រឹត្តការរំលោភផ្លូវភេទលើកដំបូង[18]។

- ការរាយការណ៍អំពីបទល្មើសរំលោភសេពន្ធវៈទៅកាន់អាជ្ញាធរភូមិ និងអង្គការក្រៅរដ្ឋាភិបាល បានបង្ហាញពីអត្រានៃការរំលោភសេពន្ធវៈគួរឱ្យកត់សម្គាល់ទៅលើមនុស្សវ័យក្មេងទាំងពីរក្រុម គឺក្រុមស្ត្រីរៀបការហើយ និងស្ត្រីមិនទាន់រៀបការដែលមានអាយុក្រោម២៥ឆ្នាំ[19]។

- ថ្មីៗនេះ Triple Jeopardy ដែលសិក្សាស្ទង់មតិទៅលើស្ត្រីពិការនៅក្នុងប្រទេសកម្ពុជា បានបង្ហាញថា ២៤,៤ភាគរយធ្លាប់ឆ្លងកាត់ការប្រើអំពើហិង្សាផ្លូវភេទពីដៃគូរបស់ពួកគេ បើធៀបទៅនឹងស្ត្រីមិនពិការ គឺមាន១៦,៨ភាគរយ។ ស្ត្រីដែលពិការ ៥,៧ភាគរយត្រូវរងគ្រោះពីការប្រើអំពើហិង្សាលើផ្លូវភេទពីសំណាក់សមាជិកគ្រួសារ បើធៀបទៅនឹងស្ត្រីដែលមិនពិការមាន ១.១ភាគរយ[20]។

- លទ្ធផលដំបូងនៃការសិក្សាទៅលើស្ត្រីប្តូរភេទប្រកបរបរផ្លូវភេទចំនួន៥០នាក់ បានបង្ហាញថា ៥៥ភាគរយ នៃអ្នកចូលរួមបានប្រាប់ពីការបង្ខិតបង្ខំឱ្យរួមភេទដោយមានប្រើសកម្មភាពផ្សេងៗជាច្រើន[21]។

[17] The sample size of respondents who experienced sexual abuse was too small to gain statistically significant estimates of the involvement of multiple perpetrators for specific types of sexual abuse such as rape. Consequently, although rape by multiple perpetrators could not be analyzed specifically, figures for all types of sexual abuse were analyzed.

[18] DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

[19] CDB Online. 2013. http://db.ncdd.gov.kh/cdbonline/home/index.castle (accessed November, December 2013); ECPAT. NGO Joint Statistics. Phnom Penh: ECPAT, 2011.

[20] Astbury, Jill and Fareen Walji. Triple Jeopardy: Gender-based violence and human rights violations experienced by women with disabilities in Cambodia. Phnom Penh: AUSAID, 2013.

[21] Davis, Janet, Hieke Lippman and Glenn Miles. More than Gender. Phnom Penh: Love 146 End Child Trafficking and Exploitation, 2013.




## ករណីបៀតបៀនកេរ្តិ៍ភេទច្រើនកើតមាននៅក្នុងកន្លែងធ្វើការ និងនៅសហមគន៍

▲ ច្បាប់កម្ពុជាហាមឃាត់គ្រប់ទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចលើកុមារ

- ការសិក្សារបស់អង្គការ CARE[22] បានបង្ហាញថា អត្រានៃការបៀតបៀនកេរ្តិ៍ភេទមានកម្រិតខ្ពស់នៅក្នុងកន្លែងធ្វើការចំពោះស្ត្រីដែលធ្វើការជាអ្នកបម្រើស្រាបៀរ ក្នុងនោះរួមមានការប៉ះពាល់រាងកាយដោយគ្មានការយល់ព្រម (៨០ភាគរយ) និងការរួមភេទដោយបង្ខំ (៣៨ភាគរយ)។
- តាមការសិក្សាថ្មីៗបន្ថែមទៀត ការប្រៀបធៀបបទពិសោធន៍នៃការរំលោភ និងការបៀតបៀនកេរ្តិ៍ភេទទៅលើស្ត្រីធ្វើការនៅក្នុងក្រុមហ៊ុនស្រាបៀរដែលជាសមាជិកក្រុមអ្នកលក់ស្រាបៀរ[23] បានរកឃើញថា ៦១ភាគរយនៃអ្នកធ្វើការដែលត្រូវបានសម្ភាសន៍បានឱ្យដឹងថា

[22] CARE Cambodia. A Report on the Situation of Beer Promotion Women in the Workplace. Phnom Penh: Care, 2005.

[23] ក្នុងខែតុលា ឆ្នាំ២០០៦ មុខរបរសំខាន់ក្នុងទីផ្សារស្រាបៀរកម្ពុជាស្របពេលនឹងការរកឃើញស្ថាប័នឧស្សាហកម្មជំនាញគេហៅថា "ឧស្សាហកម្មផ្សព្វផ្សាយស្រាបៀរកម្ពុជា"

មានការបៀតបៀនកេរ្តិ៍ភេទនៅ១២ខែ ចុងក្រោយនេះ បើធៀបទៅនឹងអ្នកដែលមិនធ្វើការនៅក្នុងក្រុមអ្នកផ្សព្វផ្សាយស្រាបៀរមាន៧៩ភាគរយ[24]។

- ថ្មីៗនេះ តាមការសិក្សាស្រាវជ្រាវរបស់អង្គការពលកម្មពិភពលោកបានបង្ហាញថាស្ត្រី១នាក់ក្នុងចំណោម៥នាក់ដែលជាកម្មករនៅក្នុងរោងចក្រកាត់ដេរ បានទទួលការបៀតបៀនកេរ្តិ៍ភេទ ឬការចំអកឡកឡឺយផ្លូវភេទ។[25]

- តាមការសិក្សារបស់អង្គការ ActionAid កម្ពុជាបានរកឃើញថា ស្ត្រីបម្រើការងារនៅតាមរោងចក្រ ប្រឈមមុខយ៉ាងខ្លាំងទៅនឹងអំពើហិង្សាគ្រប់កម្រិត។ ស្ត្រីបម្រើការងារនៅតាមរោងចក្រដែលបានធ្វើសម្ភាសន៍ជាងពាក់កណ្តាលធ្លាប់ទទួលរង ឬធ្លាប់ធ្វើជាសាក្សីអំពីការបៀតបៀនកេរ្តិ៍ភេទនៅកន្លែងធ្វើការ។ ទោះបីជាពួកគេចាកចេញពីកន្លែងធ្វើក៏ដោយ ក៏ពួកគេប្រឈមនឹងការរំលោភសេពសន្ថវៈ ការរំលោភបំពានដោយពាក្យសំដី និងការបៀតបៀនកេរ្តិ៍ភេទពីសំណាក់បុរសៗដែលនៅជុំវិញរោងចក្រ[26]។

- ទិន្នន័យដើមគ្រានៃការសិក្សាស្រាវជ្រាវរបស់អង្គការ ActionAid កម្ពុជា លើស្ត្រីចំនួន ៣៨០នាក់ ដែលបម្រើការងារនៅតាមរោងចក្រ (តាមរោងចក្រចំនួន២៤១នាក់) និសិត្សសាកលវិទ្យាល័យចំនួន ៩១នាក់ អ្នកបំរើសេវាផ្លូវភេទចំនួន២៤នាក់ ស្ត្រីធ្វើការនៅតាមក្រុមហ៊ុនស្រាបៀរចំនួន ២៤នាក់ បានរកឃើញថា ស្ត្រី៨៣នាក់ (២២ភាគរយ) ធ្លាប់ទទួលរងការបៀតបៀនកេរ្តិ៍ភេទឬរំលោភបំពានរាងកាយនៅតាមទីសាធារណៈ ៧៧ភាគរយ រំលោភបំពានដោយពាក្យសំដី ២៥ភាគរយ រំលោភបំពានរាងកាយ និង ២១ភាគរយ បានប្រើប្រាស់អំពើហិង្សាលើរាងកាយ។ ជាមធម្យម ស្ត្រីម្នាក់ៗប្រឈមនឹងឧប្បត្តិហេតុនៃការរំលោភបំពានជាលើកដំបូងចំនួន៥ដងពីសំណាក់មនុស្សដែលខ្លួនពុំធ្លាប់ស្គាល់ ឬក្មេងទំនើងដែលមានអាយុចន្លោះពី ២២ឆ្នាំ ដល់៣៥ឆ្នាំ។ ឧប្បត្តិហេតុដែលកើតមាននៅតាមដងផ្លូវមាន ៥៥ភាគរយ នៅតាមទីកន្លែងកម្សាន្ត ឬកន្លែងប្រព្រឹត្តគ្រឿងស្រវឹងមាន២៧ភាគរយ និង១៥ភាគរយ នៅតាមផ្ទះសំណាក់ ព្រមទាំង៩៧ ភាគរយមានអារម្មណ៍ថាមិនមាន

---

[24] Racz, Kritof and Samuel Grumiau. Promoting Decency? Report on the Situation of Beer Promotion Workers in Cambodia. Amsterdam: SOMO, 2012 and Grumiau, 2012.

[25] ILO. Action-oriented research on gender equality and the working and living conditions of garment factory workers in Cambodia. Phnom Penh: ILO Regional Office for Asia and the Pacific, 2012.

[26] ActionAid. Safe Cities for Women: From Reality to Rights. ActionAid, 2014.

សុវត្ថិភាពនៅពេលដែលពួកគេចេញទៅខាងក្រៅនាពេលងងឹត និង ៨៩ភាគរយមានអារម្មណ៍ថាមិនមានសុវត្ថិភាពនៅពេលដែលពួកគេចេញពីធ្វើការ ឬចេញពីសាលានៅពេលរាត្រី និង២៤ភាគរយមានអារម្មណ៍ថាមិនមានសុវត្ថិភាពពេលពួកគេនៅតាមទីសាធារណៈនានា។

- ការសិក្សាទៅលើមនុស្សប្តូរភេទដែលបំរើសេវាផ្លូវភេទ៥០នាក់ ជាស្ត្រី ឬជាភេទទីបី បានរាយការណ៍ថា ៧២ភាគរយ ធ្លាប់មានការបៀតបៀនកេរ្តិ៍ភេទ ដូចជាការប៉ះ ឬស្ទាបអង្អែលដែលពុំមានការយល់ព្រម[27]។

## ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី ឬ ក្មេងស្រី នៅតែបន្ត

- អាជីវកម្មផ្លូវភេទមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការជួញដូរមនុស្ស។ ជារឿយៗ ស្ត្រី ឬក្មេងស្រីដែលទទួលរងការកេងប្រវ័ញ្ចផ្លូវភេទ គឺជាជនរងគ្រោះដោយការជួញដូរមនុស្ស។ ការធ្វើទេសន្តប្រវេសន៍មិនមានសុវត្ថិភាព អាចធ្វើឱ្យស្ត្រីឬក្មេងស្រីធ្លាក់ទៅក្នុងគ្រោះថ្នាក់នៃការធ្វើអាជីវកម្មផ្លូវភេទ។

- របាយការណ៍នៃការសិក្សាអំពីអំពើហិង្សាលើកុមារនៅកម្ពុជា បានរកឃើញថា ១,៦ភាគរយនៃស្ត្រីដែលមានអាយុចន្លោះពី១៨ឆ្នាំ ដល់២៤ឆ្នាំ បានទទួលលុយម្ហូបអាហារ ឬវត្ថុដែលពេញចិត្ត ដើម្បីដោះដូរនឹងការរួមភេទ ឬ សកម្មភាពរួមភេទផ្សេងទៀតមុនអាយុ១៨ឆ្នាំ[28]។

- នៅក្នុងការសិក្សាស្រាវជ្រាវអ្នកធ្វើការវ័យក្មេងនៅក្លិបកម្សាន្តក្នុងទីក្រុងចំនួន៤ បានបង្ហាញថា ស្ត្រីធ្វើការនៅក្នុងក្លឹបកម្សាន្ត[29] ជាទូទៅធ្លាប់ទទួលរងអំពើហិង្សា និងការបៀតបៀនកេរ្តិ៍ភេទនៅក្នុងបរិបទនៃការធ្វើការរបស់ពួកគេ។ អតិថិជនជាធម្មតា គឺជាអ្នកបង្កអំពើហិង្សា ឬមិនចង់ប្រើប្រាស់ស្រោមអនាម័យជាពិសេសនៅពេលស្រវឹង[30] ។

- តាមការសិក្សាស្រាវជ្រាវអ្នកធ្វើការវ័យក្មេងនៅក្លិបកម្សាន្ត បានបង្ហាញថា ស្ត្រីវ័យក្មេង ភាគ ច្រើន មានអាយុ ពី១៤ឆ្នាំ ដល់១៨ឆ្នាំ បានចូលក្នុងសកម្មភាពសេពសន្ថវៈ

---

[27] Davis, Janet, Hieke Lippman and Glenn Miles. More than Gender. Phnom Penh: Love 146 End Child Trafficking and Exploitation, 2013.

[28] DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

[29] អ្នកធ្វើការក្នុងក្លិបកំសាន្តត្រូវបានកំណត់ជាអ្នករកស៊ីផ្លូវភេទដោយផ្ទាល់ និងប្រយោល

[30] MoEYS. Examining life experiences and HIV risks of Young entertainment workers in four Cambodia cities. Phnom Penh: MoEYS, 2012.

មិនមានការព្រមព្រៀងគ្នា។ ប្រហែលជា ១ភាគ៣នៃស្ត្រីធ្វើការក្នុងក្លិបកម្សាន្តត្រូវបានគេទិញភាពបរិសុទ្ធ ហើយ១ភាគ៣ ទៀតបានរាយការណ៍ថា ត្រូវបានគេចាប់រំលោភឬបង្ខំឱ្យមានការរួមភេទជាមួយមិត្តប្រុស ឪពុកចុង ឬមនុស្សចម្លែក ដែលជាការរួមភេទលើកដំបូង[31]។

- ការសិក្សាពីការប្រថុយប្រថាននៃយុវវ័យ (MARYP)[32] បានរកឃើញថា ស្ត្រី៣៧ភាគរយ ប្រឈមនឹងការប្រថុយប្រថាននៃយុវវ័យនៅចន្លោះអាយុពី១០ទៅ១៩ឆ្នាំ និង៥២ភាគរយនៃក្រុមស្ត្រីអាយុពី២០ឆ្នាំ ដល់២៤ឆ្នាំ មានទំនាក់ទំនងក្នុងអាជីវកម្មផ្លូវភេទកាលពីឆ្នាំកន្លងទៅដោយស្ត្រីនៅតាមជនបទមានអត្រាខ្ពស់ជាង[33]។
- តាមការសិក្សាមួយនៅក្នុងឆ្នាំ២០០៨ ដើម្បីវាស់វែងទំហំនៃការជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ បានប៉ាន់ប្រមាណថាមានកន្លែងធ្វើអាជីវកម្មផ្លូវភេទប្រមាណ១.២២៥កន្លែង ក្នុងនោះមាន ផ្ទះបន ហាងខារ៉ាអូខេ ភោជនីយដ្ឋាន រង្គសាល អ្នកបំរើសេវាផ្លូវភេទឯករាជ្យ (អាជីវកម្មខ្លួនឯង) និងបនល្បែង ដោយមានអ្នកបំរើសេវាផ្លូវភេទច្រើនជាង២៧.០០០នាក់ នៅក្នុងប្រទេសកម្ពុជា។ មានកន្លែងបំរើសេវាផ្លូវភេទចំនួន៨១កន្លែងជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ក្នុងនោះមានជនរងគ្រោះ ដោយការជួញដូរសម្រាប់បម្រើផ្លូវភេទប្រមាណ ១.០៥៣ នាក់[34] ។
- បេសកកម្មយុត្តិធម៌អន្តរជាតិឆ្នាំ២០១៣ ដែលបានធ្វើការសិក្សាស្រាវជ្រាវមួយស្តីពីការធ្វើអាជីវកម្មលើកុមារ បានបង្ហាញថា យ៉ាងតិច ១ភាគរយ នៃអ្នកបំរើសេវាផ្លូវភេទមានអាយុតិចជាង១៥ឆ្នាំ[35]។

## ស្ត្រី និងក្មេងស្រីខ្លះប្រឈមនឹងការកើនឡើងនូវហានិភ័យនៃអំពើហិង្សា

- ភាពអាស្រូវកេរ្តិ៍ ការបៀតបៀន ការរើសអើង កើតឡើងជាធម្មតាចំពោះស្រីស្រឡាញ់ស្រីដូចគ្នា អ្នកស្រលាញ់គ្នាទាំងពីរភេទ និងមនុស្សកែភេទនៅក្នុងប្រទេសកម្ពុជា ទោះបីជាពួកគេទទួលការរំលោភបំពាន ឬការរើសអើងជាញឹកញាប់ ក៏ប៉ុន្តែត្រូវបានមើលរំលង ឬមិនអើពើពីសំណាក់គ្រួសារ និងសហគមន៍របស់ពួកគេ[36]។

---

[31] Ibid..

[32] MARYP អ្នកទាំងនោះជាអ្នកលក់ផ្លូវភេទ អ្នកចាក់ថ្នាំញៀន និងក្មេងប្រុសដែលរួមភេទជាមនុស្សប្រុស

[33] MoEYS. Most at Risk Young People Survey. Phnom Penh: MoEYS, 2010.

[34] Steinfatt, Thomas. Measuring the Extent of Sex Trafficking in Cambodia. Bangkok: UNIAP, 2011.

[35] IJM. Commercial Sexual Exploitation of Children and the Public Justice System Respone. Phnom Penh: International Justice Mission, 2013.

[36] Cambodia Center for Human Rights. Coming out in the Kingdom: Lesbian, gay and bisexual and transgender people in Cambodia. Phnom Penh: CCHR, 2010.



▲ ច្បាប់ចែងអំពីអាជ្ញាធរត្រូវធ្វើអន្តរាគមន៍ និងការពារជនរងគ្រោះ

- តាមការសិក្សាថ្មីៗនេះទៅលើមនុស្សចំនួន១៦១នាក់ ដែលមានសមាជិកគ្រួសារធ្វើចំណាកស្រុកនៅខេត្តបាត់ដំបងបានរាយការណ៍ថា មានជិតពីរភាគបីបានធ្វើទេសន្តប្រវេសន៍ខុសច្បាប់ ហើយអត្រាស្ត្រីវ័យក្មេងធ្វើទេសន្តប្រវេសន៍មានខ្ពស់ជាងគេ ដែលជាហេតុធ្វើឱ្យពួកគេងាយរងគ្រោះនឹងការជួញដូរផ្លូវភេទ និងការរំលោភបំពានផ្សេងៗទៀត[37]។
- តាមការសិក្សាថ្មីៗនេះទៅលើមនុស្សកែភេទបំរើសេវាផ្លូវភេទចំនួន៥០នាក់ ក្នុងទីក្រុងភ្នំពេញបានបញ្ជាក់ថា ៤៦ភាគរយនៃអ្នកឆ្លើយតបបានរាយការណ៍ថា មានអំពើហិង្សាលើរាងកាយក្នុងរយៈពេល១២ខែចុងក្រោយបន្ទាប់ពីប្តូរភេទ[38]។

[37] MoWA. Study on Impacts of Migration on Families and Communities in Battambang Province. Phnom Penh: MoWA, 2014.

[38] Davis, Janet, Hieke Lippman and Glenn Miles. More than Gender. Phnom Penh: Love 146 End Child Trafficking and Exploitation, 2013.

- ការសិក្សាអំពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃមេរោគអេដស៍ ដែលបានធ្វើឡើងក្នុងប្រទេសកម្ពុជា បានបង្ហាញថា ស្ត្រីដែលផ្ទុកមេរោគអេដស៍បានរាយការណ៍ថា មានការរំលោភដោយពាក្យសំដី ការរំលោភបំពានលើរូបរាងកាយ ជាងបុរសដែលមានផ្ទុកមេរោគអេដស៍និងមនុស្សដែលគ្មានផ្ទុកមេរោគអេដស៍[39]។
- សមាគមជួយជនរងគ្រោះដោយសារទឹកអាស៊ីតកម្ពុជា (CASC) បានកត់ត្រាថា៖ ប្រមាណជា៤៥ភាគរយនៃបទឧក្រិដ្ឋ៤០០ករណីនៃការវាយប្រហារដោយសារទឹកអាស៊ីតចាប់តាំងពីឆ្នាំ១៩៦៤ គឺជាស្ត្រី។ ភាគច្រើននៃការវាយប្រហារដោយទឹកអាស៊ីត គឺកើតឡើងនៅក្នុងទីក្រុងភ្នំពេញ និងកំពង់ចាម ដោយសារតែទឹកអាស៊ីតងាយស្រួលរកទិញបាននៅក្នុងទីកន្លែងទាំងនោះ[40]។

## អំពើហិង្សាលើស្ត្រីត្រូវបានគេទទួលយក និងអត់ឱនឱ្យយ៉ាងទូលំទូលាយ

### *ការទទួលយកអំពើហិង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយ ប៉ុន្តែនៅតែមានកម្រិតខ្ពស់*

ទិន្នន័យទី១៖ ភាគរយស្ត្រី និងបុរស (១៥-៤៩) បានយល់ស្របទៅលើហេតុផលយ៉ាងតិចមួយ ដែលនិយាយថាបុរសអាចវាយប្រពន្ធបាន




*ប្រភព៖ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០*

[39] National Aids Authority. Socio-economic Impact and Macroeconomic Impact of HIV in Cambodia. Phnom Penh: United Nations, 2010.

[40] CASC. Statistics of Acid Burns in Cambodia . Phnom Penh: Cambodia Acid Survivors Charity, 2013.

- ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០១០ រាយការណ៍ថា ប្រហែលពាក់កណ្តាលនៃស្ត្រី និង១ភាគ៤ នៃបុរស ដែលមានអាយុពី១៥ឆ្នាំ ដល់៤៩ឆ្នាំ បានយល់ស្របទៅលើហេតុផលយ៉ាងតិចមួយ ដែលនិយាយដោះសារថា បុរសអាចវាយប្រពន្ធរបស់គាត់បាន។ និន្នាការវិជ្ជមាន មួយ គឺភាគរយនៃស្ត្រីដែលយល់ស្របថា មានហេតុផលមួយអាចវាយបាន គឺមានការថយចុះពី ៥៥ភាគរយ ក្នុងឆ្នាំ២០០៥ មកនៅ៤៥,៧ភាគរយ ក្នុងឆ្នាំ២០១០[41]។

- សរុបមក ការប្រៀបធៀបទៅនឹងឆ្នាំ២០០៥ តាមការអង្កេតតាមដានដែលធ្វើឡើងដោយក្រសួងកិច្ចការនារី ឆ្នាំ២០០៩ បានបង្ហាញថា ប្រជាជនភាគតិចបានទទួលស្គាល់ថា អំពើហិង្សាជាអំពើដែលអាចទទួលយកបាន និងប្រជាពលរដ្ឋភាគច្រើនទៀតបានទទួលស្គាល់ថា ការប្រព្រឹត្តអំពើហិង្សាជាការខុសច្បាប់[42]។

- តាមការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាបានបង្ហាញថា ប្រហែល ២ភាគ៥នៃស្ត្រីដែលមានអាយុចាប់ពី ១៣ឆ្នាំដល់១៧ឆ្នាំ និង១ភាគ៣នៃស្ត្រីដែលមានអាយុចាប់ពី ១៨ឆ្នាំដល់២៤ឆ្នាំ បានយល់ស្របថា ប្តីអាចវាយប្រពន្ធរបស់គាត់បានក្រោមហេតុផលមួយឬច្រើន។ បុរសប្រហែលពីរនាក់ក្នុងចំណោមប្រាំនាក់ ដែលមានអាយុចាប់ពី ១៣ឆ្នាំដល់១៧ឆ្នាំ និងបុរសច្រើនជាងម្នាក់ក្នុងចំណោមបីនាក់ដែលមានអាយុចាបើពី១៨ឆ្នាំដល់២៤ឆ្នាំបានឯកភាពថា ប្តីអាចវាយប្រពន្ធរបស់គាត់បានក្រោមហេតុផលមួយឬច្រើន[43] ។

- ស្ត្រីប្រហែលម្នាក់ក្នុងចំណោមបួននាក់ដែលមានអាយុចាប់ពី ១៨ឆ្នាំដល់ ២៤ឆ្នាំ (២៤ភាគរយ) បានឆ្លើយថា ពេលដែលពួកគាត់ជួបឧបទ្ទវហេតុរំលោភផ្លូវភេទនៅផ្ទះ គឺមានម្តាយនៅផ្ទះ និងម្នាក់ក្នុង ចំណោមប្រាំនាក់ (១៩,៧ភាគរយ) បានឆ្លើយថា មានកូនក្មេងតូចៗនៅផ្ទះ[44]។

- កម្មវិធីដៃគូដើម្បីការទប់ស្កាត់ បានធ្វើការសិក្សាលើការប្រើអំពើហិង្សារបស់បុរសទៅលើស្ត្រីបានឱ្យដឹងថា មាន៣២,៨ភាគរយនៃស្ត្រី ហើយ២៧ភាគរយនៃបុរស

41 NIS. CDHS. Phnom Penh: Ministry of Planning, 2010.

42 MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

43 ការយល់ព្រមទទួលយកថាប្តីវាយប្រពន្ធរបស់ខ្លួននោះគឺប្រសិនបើប្រពន្ធចេញទៅក្រៅដោយមិនបានប្រាប់ប្តី មិនយកចិត្តទុកដាក់នឹងកូន ឈ្លោះជាមួយប្តី បដិសេធន៍មិនព្រមរួមភេទជាមួយប្តី ឬធ្វើម្ហូបមិនឆ្ងាញ់សម្រាប់ប្តី

44 Ibid.

យល់ស្របថា មានពេលខ្លះស្ត្រីសមនឹងទទួលការវាយដំនេះ[45]។

- តាមការសិក្សាបែបគុណភាពទៅលើភាពជាបុរស បានបង្ហាញថា ១០០ភាគរយនៃបុរសគិតថា បុរស ដែលប្រើអំពើហិង្សា គឺមិនល្អ ហើយជនដែលប្រព្រឹត្តគួរតែទទួលទោស ប៉ុន្តែ៥៤ភាគរយ យល់ស្របថាបុរសជាអ្នកមានសិទ្ធិអំណាច និងប្រព្រឹត្តនូវអំពើហិង្សា ប្រសិនបើប្រពន្ធរបស់គាត់មិនស្តាប់បង្គាប់គាត់[46]។

## ខណៈដែលការរំលោភសេពសន្ថវៈត្រូវបានចាត់ទុកយ៉ាងទូលាយថា ជាបទឧក្រិដ្ឋនោះ ស្ត្រី និងក្មេងស្រីនៅតែទទួលនូវការស្តីបន្ទោសចំពោះការធ្វើខ្លួនឱ្យងាយរងគ្រោះ និងទទួលរងនូវភាពអាស្រូវកេរ្តិ៍យ៉ាងធ្ងន់ធ្ងរក្នុងសង្គម

- ការរំលោភសេពសន្ថវៈ គឺត្រូវបានគេយល់ថា មានការទទួលយកតិចជាងអំពើហិង្សារវាងប្តី ឬប្រពន្ធ និងត្រូវបានគេមើលឃើញថា ជាបទឧក្រិដ្ឋដែលសមនឹងដាក់ទោសតាមច្បាប់។ តាមការអង្កេតតាមដានឆ្នាំ២០០៩ ប្រជាពលរដ្ឋភាគច្រើនបាននិយាយថា អ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ គួរតែត្រូវបានដាក់ទណ្ឌកម្មឱ្យជាប់ពន្ធគារច្រើនជាង៣ឆ្នាំ។ ៩៧ភាគរយ យល់ថាត្រូវដាក់ទោសឱ្យជាប់ពន្ធនាគារចំពោះការរំលោភពីក្រុមក្មេងស្ទាវ និង ៩១ភាគរយចំពោះឪពុកដែលរំលោភកូនខ្លួនឯង[47]។

- ការរំលោភក្នុងចំណងអាពាហ៍ពិពាហ៍ឬដោយដៃគូដែលមិនច្បាស់លាស់ គឺត្រូវបានគេយល់ថា សមនឹងទទួលទោសតិចជាង។ មានតែ៤៩ភាគរយប៉ុណ្ណោះដែលគិតថា ការរំលោភគួរត្រូវបានដាក់ទោសជាប់ពន្ធនាគារ ប្រសិនបើករណីនេះប្រព្រឹត្តដោយដៃគូសង្សារ និង១២ភាគរយនិយាយ ថាប្តីមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួនរួមភេទ។ ចំពោះស្ត្រីដែលស្ថិតនៅក្នុងភាពក្រីក្រ ភាគរយនៃការរំលោភនេះមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់[48]។

- ខណៈដែលជនល្មើសអាចបន្តការរស់នៅដោយគ្មានការដាក់ទោសពីសង្គមនោះ ជន

[45] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

[46] Brereton, Helen and Vannak Lim. Men's Talk: Men's Attitudes Towards Men, Women, and Violence Against Women in Cambodia. Melbourne: International Women's Development Agency, 2009.

[47] MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

[48] Ibid.

រងគ្រោះត្រូវបានចាត់ទុកថាជាស្ត្រីគ្មានតម្លៃ ដែលវាជាស្ថានភាពមួយនាំឱ្យមានភាពអាម៉ាស់និងជាទណ្ឌកម្មយ៉ាងធ្ងន់ដល់ស្ត្រី ដែលបង្ខំឱ្យគេរក្សាការសម្ងាត់ពីការរំលោភ រំលោភក្នុងចំណងអាពាហ៍ពិពាហ៍ ឬក៏ចាកចោលក្រុមគ្រួសារដើម្បីការពារកិត្តិយសគ្រួសារ។ ការចូលបម្រើការងារជាអ្នកបំរើសេវាផ្លូវភេទអាចជាជម្រើសមួយ សម្រាប់ជួយរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ[49]។

- កម្មវិធីដៃគូដើម្បីការទប់ស្កាត់ ឆ្នាំ២០១២ បុរស១៨ភាគរយ និងស្ត្រី២១ភាគរយនិយាយថា ពេលដែលស្ត្រីត្រូវបានគេចាប់រំលោភនោះ ស្ត្រីតែងតែបានទទួលការស្តីបន្ទោសថា បានដាក់ខ្លួនឯងក្នុងស្ថានភាពមួយដែលងាយរងគ្រោះ[50]។

- តាមការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា បានរកឃើញថាមានស្ត្រីប្រមាណ៤៩ភាគរយ និងបុរស៧៩ភាគរយ ដែលមានអាយុចាប់ពី១៨ឆ្នាំដល់២៤ឆ្នាំ ព្រមទាំងក្មេងស្រី ៤៦ភាគរយ និងក្មេងប្រុស ៨៧ភាគរយ ដែលមានអាយុចាប់ពី១៣ឆ្នាំដល់១៧ឆ្នាំ ដែលធ្លាប់ទទួលរងគ្រោះពីការបំពានផ្លូវភេទនោះ មិនបានប្រាប់អ្នកណាម្នាក់ឱ្យដឹងពីហេតុការណ៍ដែលកើតឡើងលើរូបគេនោះទេ។ ស្ត្រីមិនដែលបានរាយការណ៍ថាមានការបំពានផ្លូវភេទដោយសារតែពួកគាត់ខ្លាចទទួលបាននូវការរំខានឬអុកឡុក និងពួកគាត់មានអារម្មណ៍ថា ការបំពានផ្លូវភេទជាកំហុសរបស់ពួកគាត់[51]។

- ការសិក្សាភ្ជាប់អំពើអាសអាភាសជាមួយអំពើហិង្សាផ្លូវភេទ បានបញ្ជាក់ថា ក្មេងប្រុសនិងក្មេងស្រី ដែលបានឃើញយ៉ាងច្បាស់នូវអំពើអាសអាភាសនៃអំពើហិង្សាផ្លូវភេទបានធ្វើឱ្យពួកគេប្រព្រឹត្ត រួមភេទនៅក្នុងវ័យកុមារភាព និងបង្រៀនក្មេងប្រុសឱ្យប្រើហិង្សា និងមានឥរិយាបថបំពានផ្លូវភេទ[52]។

- កម្មវិធីដៃគូដើម្បីការទប់ស្កាត់ បង្ហាញថា បុរសជាជនល្មើសនៃការរំលោភសេពសន្ថវៈបានទទួលស្គាល់ថា ការជំរុញឱ្យមានការចាប់រំលោភសេពសន្ថវៈ គឺពួកគេចង់ប្រព្រឹត្ត

[49] Brown, Eleanor. The Ties That Bind, Migration and Trafficking of Women and Girls for Sexual Exploitation in Cambodia. Phnom Penh: IOM, 2007.

[50] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

[51] DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

[52] Fordham, Dr. Graham. "Wise Before their Time". Phnom Penh: World Vision, 2005.

មានអារម្មណ៍ថាចង់ប្រព្រឹត្ត និងមានអារម្មណ៍ថាចង់សប្បាយ ឬជាការដាក់ទណ្ឌកម្មលើស្ត្រី។ មានបុរសមួយចំនួនតូចប៉ុណ្ណោះដែលទទួលបាននូវការដាក់ពិន័យនិងទណ្ឌកម្មតាមផ្លូវច្បាប់ ដោយសារតែវប្បធម៌និទណ្ឌភាព។ នេះមកពីមានកង្វះខាតនៃការដាក់ពិន័យ និងទណ្ឌកម្មតាមផ្លូវច្បាប់ដល់បុរសដែលមានឥរិយាបថមិនសមរម្យមួយចំនួនលើស្ត្រី រួមទាំងឥរិយាបថដែលថា ស្ត្រីមួយចំនួនមិនល្អ សមនឹងទទួលអំពើប្រព្រឹត្តបទឧក្រិដ្ឋរបស់ជនល្មើស[53] ។

## អំពើហិង្សាលើស្ត្រីកើតមានដោយសារមូលហេតុជាច្រើនរួមទាំងផ្នត់គំនិតយេនឌ័រ និងកត្តាផ្សេងៗទៀតរបស់បុគ្គល ដូចជា ការញៀនគ្រឿងស្រវឹង កម្រិតនៃការអប់រំទាប និងការទទួលរងនូវអំពើហិង្សាកាលនៅវ័យកុមារ

- ក្នុងប្រទេសកម្ពុជា បទដ្ឋានសង្គមជាប្រពៃណី និងទំនៀមទំលាប់ត្រូវបានចែងនៅក្នុង«ច្បាប់ស្រី»។ វាបានចាក់ឫសយ៉ាងជ្រៅទៅក្នុងវប្បធម៌របស់ប្រជាជនកម្ពុជា ដែលបានសិក្សាតាំងពីកុមារភាពមក និងនៅតែបន្តគ្មានទីបញ្ចប់ក្នុងផ្នត់គំនិតសង្គម។ អំពើហិង្សាលើស្ត្រីនិងកុមារដែលបានរាយការណ៍ គឺឆ្លើយតបទៅនឹងច្បាប់នោះ[54]។

- ភាពលំអៀងនៃឥរិយាបថយេនឌ័រក្នុងការប្រព្រឹត្តហិង្សាផ្លូវភេទ និងអំពើហិង្សាដោយដៃគូស្និតស្នាលមិនមានភាពខុសគ្នាដោយភេទ ឬអាយុនោះទេ មានស្ត្រី៩នាក់ក្នុងចំណោម១០នាក់ នៅគ្រប់អាយុទាំងអស់យល់ស្របថាមានឥរិយាថយេនឌ័រអវិជ្ជមានយ៉ាងហោចណាស់មួយ[55]។

- តាមការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា នៅក្នុងសមាសភាគបែបគុណភាព បានរកឃើញថា ហេតុផលសំខាន់ក្នុងចំណោមក្មេងស្រី និងស្ត្រីវ័យក្មេងមិនស្វែងរកជំនួយ ពីព្រោះពួកគេខ្លាចត្រូវបានគេរិះគន់ និងប៉ះពាល់កេរ្តិ៍ឈ្មោះ («ធ្វើខ្លួនឯងឱ្យស្អាតស្អំ» មុននឹងអ្នកនិយាយអាក្រក់ពីអ្នកដទៃ)។ ជាការមួយលំបាកក្នុងការនិយាយអំពីអំពើហិង្សាផ្លូវភេទ ពីព្រោះគឺជារឿងដែលមិនអាចទទួល

[53] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

[54] Brickell, K. Fire in the House: Gendered Experiences of Drunkeness and Violence in Siem Reap, Cambodia. Phnom Penh: Geoforum, 2008.

[55] The Cambodia Violence Against Children Survey.

យកបានសម្រាប់យុវនារី[56]។

- ការសិក្សានានាកំពុងព្យាយាមកំណត់អំពីបញ្ហាដែលជាឫសគល់នៃអំពើហិង្សាលើស្ត្រីនិងកុមារ។ ការសិក្សាតាមបែបគុណភាពមួយដោយអង្គការយេនឌ័រនិងការអភិវឌ្ឍន៍កម្ពុជា បានបង្ហាញថា បុរសត្រូវបានគេរំពឹងថាជាអ្នកបំពេញតួនាទីជាមេគ្រួសារ ជាអ្នករកស៊ីចិញ្ចឹមគ្រួសារ ជាអ្នកការពារស្ត្រីនិងកុមារ ជាអ្នកគ្រប់គ្រងលើស្ត្រីនិងកុមារ និងជាមនុស្សរឹងមាំនិងក្លាហាន[57]។ តាមកម្មវិធី ដៃគូដើម្បីការទប់ស្កាត់ឆ្នាំ២០១២ បានគាំទ្រលើចំណុចទាំងនេះដោយមានបុរស ៦២.៦ភាគរយ និងស្ត្រី៥៧.១ភាគរយ យល់ស្របថា បុរសគួរតែជាអ្នកសម្រេចលើរាល់បញ្ហាទាំងអស់នៅក្នុងគ្រួសារ[58]។

- បទដ្ឋានសង្គមជាប្រពៃណីបានបង្ហាញនៅក្នុងការត្រួតពិនិត្យ ការធ្វើចលនារបស់ស្ត្រី។ សារៈសំខាន់នៃកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់ស្ត្រីទាក់ទងនឹងផ្លូវភេទ រួមជាមួយនឹងការភ័យខ្លាចពីការចាប់រំលោភ បានដាក់កំហិតលើការធ្វើចលនារបស់ស្ត្រីនិងកុមារដែលជាលទ្ធផលនៃការទទួលឱកាសសិក្សារៀនសូត្រ និងការងារមានកម្រិតទាប[59]។

- តាមការសិក្សាលើការវិភាគទិន្នន័យរបស់ការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០៥ បានរកឃើញថា ការត្រួតត្រារបស់ប្ដីអាចនឹងធ្វើឱ្យមានការកើនឡើងនៃអំពើហិង្សាផ្លូវកាយនិងផ្លូវចិត្ត[60]។

- ការប្រើប្រាស់គ្រឿងស្រវឹងជារឿយៗ តែងតែត្រូវបានស្ដីបន្ទោសថានាំឱ្យមានអំពើហិង្សាលើស្ត្រី និងកុមារ។ ទោះបីជាយ៉ាងនេះក្ដី នៅពេលដែលប្រើប្រាស់គ្រឿងស្រវឹងវាអាចជំរុញឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរ។ ឥរិយាបថនៃការស្រវឹងបានគ្របដណ្ដប់លើបទដ្ឋានវប្បធម៌ ជាងផលប៉ះពាល់នៃជាតិស្រវឹងពិតប្រាកដ[61]។

---

56 DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

57 Gender and Development for Cambodia. Deoum Troung Pram Hath in Modern Cambodia. Phnom Penh: GADC, 2010.

58 Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

59 Strategic Asia. Gender and Human Capital Development. Phnom Penh: UNDP, 2013.

60 Eng, Sothy, Yingli Li, Miriam Ulsow and Judith Fischer. "Domestic Violence Against Women in Cambodia: Husband's Control, Frequency of Spousal Discussion and Domestic Violence Reported by Cambodian Women." Journal of Family Violence, 2010: 237-246.

61 Brickell, K. Fire in the House: Gendered Experiences of Drunkeness and Violence in Siem Reap, Cambodia. Phnom Penh: Geoforum, 2008.

## អំពើហិង្សាលើស្ត្រី និងកុមារ មានទំនាក់ទំនងនឹងគ្នា

- បទដ្ឋានសង្គមដែលរួមចំណែកធ្វើឱ្យឱ្យមានបទល្មើសនិងការអត់ឱនលើអំពើហិង្សាលើស្ត្រីនិងកុមារត្រូវបានសិក្សាតាំងពីកុមារភាព។ ក្មេងៗបានឃើញអំពើហិង្សាថាជាវិធីសាស្ត្រដ៏សាមញ្ញមួយក្នុង ការដោះស្រាយទំនាស់ដែលទំនងជារៀនសូត្រឱ្យទទួលយកថា ជាអាកប្បកិរិយាធម្មតាមួយ។

- ស្ត្រីជាច្រើនដែលទទួលរងនូវអំពើហិង្សាមិនត្រឹមតែមានកូនៗជាសាក្សីប៉ុណ្ណោះ ថែមទាំងពួកគេអាចទទួលរងនូវភាពប្រថុយប្រថានពីអំពើហិង្សា និងការរំលោភបំពានខ្ពស់ទៀតផង។

- កុមារភាពដែលទទួលរងនូវអំពើហិង្សា មានការកើនឡើងនូវភាពប្រថុយប្រថានជាជនរងគ្រោះ ឬជាដៃគូដ៏ស្និទ្ធស្នាលជាមួយជនល្មើសក្នុងជីវិតយុវវ័យរបស់ពួកគេ។

- កម្មវិធីដៃគូដើម្បីការទប់ស្កាត់ឆ្នាំ២០១២បានបង្ហាញថា បុរសដែលត្រូវបានទទួលរងអំពើហិង្សាកាលនៅកុមារ ទំនងជាប្រព្រឹត្តហិង្សាលើដៃគូរបស់ខ្លួនច្រើនជាងបុរសដែលមិនធ្លាប់ទទួលរងនូវ អំពើហិង្សាកាលពីកុមារភាព[62]។

## អំពើហិង្សានាំមកនូវការខាតបង់យ៉ាងធំធេងសម្រាប់បុគ្គល សង្គម ក៏ដូចជាសេវាសាធារណៈ រួមទាំងការខាតបង់ប្រាក់បៀវត្សរ៍ ការសិក្សា និងការចំណាយផ្សេងៗទៀត នៅពេលត្រូវឈប់សម្រាកព្យាបាល

- តាមការស្រាវជ្រាវបានបង្ហាញថា ការចំណាយផ្នែកសេដ្ឋកិច្ច និងសង្គមលើអំពើហិង្សាលើស្ត្រី និងកុមារ មានទំហំធំ និងមានប៉ះពាល់ខ្លាំងទៅក្នុងសង្គម ។ នៅខណៈដែលអំពើហិង្សាលើស្ត្រី និងកុមារបង្ហាញពីគ្រោះថ្នាក់ធ្ងន់ធ្ងរ ដូចជា មានឃាតកម្ម ឬអត្តឃាត និងមានស្ត្រីច្រើនទៀតមានរបួស និងរងនូវការឈឺចាប់ពីបញ្ហាសុខភាព[63]។

- ការសិក្សាពីភាពក្រីក្រក្នុងប្រទេសកម្ពុជាបានបង្ហាញថា អំពើហិង្សាលើស្ត្រីនិងកុមារចូលរួមចំណែកជំរុញធ្វើឱ្យមានភាពក្រីក្រ ដោយសារការបាត់បង់ប្រាក់ចំណូល និងទ្រព្យសម្បត្តិ ការចំណាយលើការឈឺថ្កាត់ និងរបួសស្នាម ការលែងលះ និងការបែក

[62] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

[63] World Health Organization, 2013.

បាក់គ្រួសារ។ បំណុល និងភាពក្រីក្រក៏បានធ្វើឱ្យស្ត្រី និងកុមារីធ្លាក់ក្នុងភាពងាយរងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទផងដែរ[64]។

- ក្នុងប្រទេសកម្ពុជា ស្ត្រីប្រហែល២០ភាគរយ ដែលធ្លាប់ទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ បានរាយការណ៍ថា ពួកគេ និងកូនៗខកខានការងារ និងការរៀនសូត្រ។ ច្រើនជាងពាក់កណ្តាលនៃសំណាកគំរូ ក៏បានរាយការណ៍ផងដែរថា មានការទទួលរងការឈឺចាប់ផ្នែកផ្លូវចិត្ត ដូចជា ឆាប់ខឹង គេងមិនលក់ អន្ទះសារ ការភ័យខ្លាច ឬការមិនសប្បាយចិត្ត ដែលនេះជាផលប៉ះពាល់ពីអំពើហិង្សាក្នុងគ្រួសារ[65]។

- តាមការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា បានរកឃើញថាការទទួលរងអំពើហិង្សាកាលពីកុមារភាព មានការទាក់ទងគ្នាជាមួយបញ្ហាសុខភាព រួមមានទុក្ខព្រួយផ្លូវចិត្ត ការឆ្លងជំងឺកាមរោគ បង្ករបួសស្នាមខ្លួនឯង និងចង់ធ្វើអត្តឃាត [66]។

## ទោះជាមានវិធានការច្បាប់ និងគោលនយោបាយសំខាន់ៗក៏ដោយ ប៉ុន្តែការអនុវត្តន៍នៅតែមានភាពខ្វះចន្លោះ

- ទោះបីជាមានភាពជឿនលឿនច្រើនក្នុងក្របខណ្ឌគោលនយោបាយក្នុងរយៈពេលប៉ុន្មានឆ្នាំនេះក៏ដោយ ក៏កិច្ចការពារតាមផ្លូវច្បាប់ចំពោះស្ត្រីរងគ្រោះដោយសារអំពើហិង្សា នៅតែប្រឈមមុខនឹងឧបសគ្គដោយសារតែការអនុវត្តន៍ច្បាប់នៅមានកម្រិតនៅឡើយ។ ទាំងនេះដោយសារតែការខ្វះកិច្ចសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាខ្វះការសិក្សាស្រាវជ្រាវអំពីធនធាន និងជំនាញ ព្រមទាំងគោលការណ៍ណែនាំច្បាស់លាស់ដើម្បីជំរុញការអនុវត្តន៍ច្បាប់។

- ការអនុវត្តន៍ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដោយសារច្បាប់នេះនៅមានភាពខ្វះចន្លោះ ដូចជាការរៀបចំឱ្យមានអនុក្រឹត្យ ស្តីពីសេចក្តីសម្រេចរដ្ឋបាលដែលចេញដោយអាជ្ញាធរមូលដ្ឋានលើករណីនៃអំពើហិង្សាក្នុងគ្រួសារ នៅមិនទាន់ចេញជា

[64] FitzGerald, Ingrid and So Sovannarith. Moving Out of Poverty: Trends in Community Well-being and Household Mobility in Nine Cambodian Villages. Phnom Penh: Cambodia Development Resource Institute, 2007.

[65] MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

[66] DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

រូបរាងនៅឡើយ និងពុំទាន់មានគោលការណ៍ណែនាំច្បាស់លាស់ ក្នុងការកំណត់ករណីអំពើហិង្សាក្នុងគ្រួសារបែបណាខ្លះដែលជាបទល្មើសព្រហ្មទណ្ឌ ជាពិសេសកម្រិតធ្ងន់ ឬស្រាល។

- គោលនយោបាយស្តីពីបត្យាប័ណ និងក្របខណ្ឌច្បាប់ខុសៗគ្នាក្នុងការដាក់ទោសនៃបណ្តាប្រទេសដែលឆ្លងកាត់ គឺជាឧបសគ្គក្នុងការខិតខំប្រឹងប្រែងទប់ស្កាត់ការជួញដូរ។

- សមត្ថភាពរបស់មន្ត្រីប៉ូលីសក្នុងការឃ្លាំមើល និងការស៊ើបអង្កេតបែបបើកចំហលើករណីមួយចំនួននៅមានកម្រិតនៅឡើយ ហើយសកម្មភាពនេះក៏មិនមានចែងច្បាស់លាស់នៅក្នុងច្បាប់។

- ការកំណត់និយមន័យមិនច្បាស់លាស់ ស្តីពីភាពជាអាណាព្យាបាលសម្រាប់ការថែទាំកុមាររងគ្រោះ គឺជាជម្រើសតែមួយគត់។

- ទោះបីច្បាប់ទេសចរណ៍ហាមឃាតក្រុមដែលមិនទាន់គ្រប់អាយុ មិនឱ្យចូលទៅក្នុងមជ្ឈមណ្ឌលកម្សាន្តរបស់មនុស្សពេញវ័យក៏ដោយ ប៉ុន្តែច្បាប់នេះមិនបានបញ្ជាក់ច្បាស់លាស់ ថាតើមជ្ឈមណ្ឌលកម្សាន្តរបស់មនុស្សពេញវ័យនោះគ្របដណ្តប់អ្វីខ្លះឡើយ។

- ការបង្កើតកន្លែងបំរើសេវាផ្លូវភេទ ត្រូវបានផ្តន្ទាទោសដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ ប៉ុន្តែច្បាប់ទាំងនេះមិនបានគ្របដណ្តប់អំពីស្ថានភាពដែលក្រុមមួយចំនួនតូចជួបប្រទះ ដូចជា ជារឿយៗស្ត្រីទាំងនោះតែងតែទទួលរងសម្ពាធ ឬការកៀបសង្កត់ពីនិយោជករបស់ខ្លួនសម្រាប់ការកម្សាន្តសប្បាយ និង ត្រូវបានភ្ញៀវមួយចំនួនយកទៅខាងក្រៅក្នុងគោលបំណងដើម្បីរួមភេទ។

- ការបៀតបៀនកេរ្តិ៍ភេទត្រូវបានហាមឃាត់ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ការងារ ប៉ុន្តែ ការកំណត់និយមន័យនៅមិនទាន់បានច្បាស់លាស់នៅឡើយ។

- នៅក្នុងមាត្រា១០៤៥ នៃក្រមរដ្ឋប្បវេណីបានដាក់វិសាលភាពសំខាន់ដោយអនុញ្ញាតឱ្យអាណាព្យាបាល ឬមាតាបិតាមានឥទ្ធិពលលើការអប់រំ ដាក់ទណ្ឌកម្មកូន ហើយក៏មិនមានគោលនយោបាយ ឬក៏ការរាយការណ៍ណាបញ្ជាក់ច្បាស់លាស់អំពីការរំលោភបំពានលើកុមារតាមរយៈក្រុមអ្នកជំនាញនៅឡើយទេ។

## ជម្រើសនានាសម្រាប់គាំទ្រ និងដោះស្រាយអំពើហិង្សាលើស្ត្រី និងកុមារនៅមានកម្រិត

- ភាគច្រើន នៃអ្នករងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងកុមារ មិនសូវបានបញ្ចេញឱ្យឃើញ និងមិនបានស្វែងរកជំនួយពីនរណាម្នាក់នោះទេ ។ នៅក្នុងការអង្កេតពិនិត្យតាមដាន ឆ្នាំ២០០៩ របស់ក្រសួងកិច្ចការនារីបានឱ្យដឹងថា ៨៧ភាគរយនៃជនរងគ្រោះដោយ សារការរំលោភសេពសន្ថវៈ មិនបានស្វែងរកជំនួយនោះទេ និង ៨១ភាគរយ នៃជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារបាន«រក្សាភាពស្ងៀមស្ងាត់»[67]។

- ការសិក្សាស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា បានរកឃើញថា ស្ត្រីដែលរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ ឬហិង្សាផ្លូវកាយភាគច្រើនមិនបានប្រាប់នរណាម្នាក់អំពីគ្រោះថ្នាក់នេះឡើយ ហើយមានតែចំនួនតិចតួចបំផុតដែលពួកគេបានទៅរកជំនួយ[68]។

- ច្បាប់ដែលពាក់ព័ន្ធនឹងស្ត្រី និងការសិក្សាស្តីពីអំពើហិង្សាក្នុងគ្រួសារ (ស្ត្រីចំនួន ១០០០) បានរកឃើញថា មាន៧៦ភាគរយ នៃជនរងគ្រោះដោយសារអំពើហិង្សាលើរាងកាយ និង៦៨ភាគរយ នៃជនរងគ្រោះដោយសារអំពើហិង្សាផ្លូវចិត្តមិនដែលបានស្វែងរកជំនួយនោះទេ[69]។

- ការសិក្សាស្តីពីក្រុមស្ត្រីពិការបានឱ្យដឹងថា មាន៦៨ភាគរយនៃស្ត្រីពិការ ធៀបទៅនឹងក្រុមស្ត្រីដែលមិនពិការ មាន៤៣.៨ភាគរយ បាននិយាយថាគ្មាននរណាម្នាក់ទទួលរងអំពើហិង្សាពីដៃគូរបស់គេឡើយ[70]។

---

67 MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

68 DRAFT VAC. Draft Findings Violence Against Children Survey. Phnom Penh: MoWA, 2014.

69 Brickell, K., B. Prak and B. Poch. "Domestic Violence Law: The Gap Betwee Legislation and Practice in Cambodia and What Can Be Done About it." 1 19, 2014. http://www.katherinebrickell.com/2014/01/19/new-research-report-on-domestic-violence-law-in-cambodia/ (accessed February 11, 2014).

70 Astbury, Jill, and Fareen Walji. *Triple Jeopardy: Gender-based violence and human rights violations experienced by women with disabilities in Cambodia.* Phnom Penh: AUSAID, 2013.

## វិសមភាពយេនឌ័រ កង្វះខាតផ្នែកធនធាន និងវគ្គបណ្តុះបណ្តាល និងវប្បធម៌និទណ្ឌភាព ជួយជំរុញដល់ការអនុវត្តន៍នូវទម្លាប់នានា ដូចជាការសម្រុះសម្រួលករណីអំពើហិង្សាក្នុងគ្រួសារ និងការទូរទាត់សំណងនៅក្នុងករណីចាប់រំលោភសេពសន្ថវៈ

- អាជ្ញាធរមូលដ្ឋាន (រួមទាំងប៉ូលីស) គឺជាតួអង្គសំខាន់បន្ទាប់ពីក្រុមគ្រួសាររបស់ពួកគេ សម្រាប់ស្ត្រីដើម្បីស្វែងរកជំនួយ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរមូលដ្ឋាននៅតែរក្សាអាកប្បកិរិយាដូចពីមុនដដែលអំពីអំពើហិង្សាលើស្ត្រី និងកុមារ។ យោងតាមការអង្កេតពិនិត្យតាមដាន ឆ្នាំ២០០៩ របស់ក្រសួងកិច្ចការនារីឃើញថា អាជ្ញាធរមូលដ្ឋានច្រើនជាងមួយភាគបី (១/៣) បាននិយាយថា ប្តីអាចប្រព្រឹត្តអំពើហិង្សាលើប្រពន្ធ គឺជារឿងត្រឹមត្រូវ ប្រសិនបើប្រពន្ធនោះមិនព្រមស្តាប់បង្គាប់ប្តី[71] ។

- នៅពេលដែលមន្ត្រីនគរបាលជាតិបង្កើតរចនាសម្ព័ន្ធដើម្បីទប់ស្កាត់ និងលើកកម្ពស់ការឆ្លើយតបរបស់ប៉ូលីស ជាពិសេស ការស៊ើបអង្កេតនៃការជួញដូរមនុស្ស មិនបានធ្វើឡើងមិនទាន់ពេលវេលា និងប៉ូលីសខ្វះមធ្យោបាយធ្វើដំណើរ ព្រមទាំងសម្ភារៈដែលត្រូវការចាំបាច់មួយចំនួន ដូចជា ឧបករណ៍សម្រាប់ធ្វើការប្រមូលភស្តុតាង។

- អំពើហិង្សាក្នុងគ្រួសារត្រូវបានការចាត់ថ្នាក់ជាបទល្មើសព្រហ្មទណ្ឌដែលពុំទាន់បានចែងច្បាស់ក្នុងក្របខ័ណ្ឌច្បាប់[72] និងខ្វះគោលការណ៍ជាក់លាក់សម្រាប់អន្តរាគមន៍ខ្វះជំនាញ និងធនធានសម្រាប់អនុវត្តការកំណត់ប្រភេទនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ថា «ធ្ងន់ធ្ងរ» និង «មិនធ្ងន់ធ្ងរ» ដែលអនុវត្តដោយនគរបាល និងអាជ្ញាធរ។ ក្នុងករណី «មិនធ្ងន់ធ្ងរ» អាជ្ញាធរមូលដ្ឋានតែងតែប្រើវិធីសាស្ត្រ "សម្រុះសម្រួល" ដែលយកទៅអនុវត្តក្នុងកិច្ចការពារស្ត្រីនៅក្នុងប្រពន្ធ័តុលាការក្រៅពីការសងជំងឺចិត្ត[73]។

---

[71] MoWA. Follow Up Survey, Violence Against Women. Phnom Penh: MoWA, 2009.

[72] The 2005 DV Law provides that when both parties agree, reconciliation or mediation can be pursued in cases of minor misdemeanours or petty crimes, as well as violent acts causing mental or economic harm. There is, however, no definition for minor misdemeanours and petty crimes in the DV Law. In the case of domestic violence, a criminal investigation, prosecution and conviction is possible, not on the basis of the DV Law but instead pursuant to the *Penal Code*. In the absence of any protocols or sub-decrees, authorities interpret and apply the law within prevailing social norms and cultural practices.

[73] Lim, J. Out of court resolutions of violence against women. Phnom Penh: European Union/Dan Church Aid, 2009.

- ប្រសិនបើមានស្ត្រីណាម្នាក់ទទួលបាននូវសំណង តាមរយៈតុលាការ អត្រានៃការដក ពាក្យបណ្តឹងទាំងនោះភាគច្រើន គឺជាអ្នកក្រីក្របំផុត។ នៅក្នុងឆ្នាំ២០១០ ទីភ្នាក់ងារ សហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) បានធ្វើការសិក្សា ស្រាវជ្រាវរកឃើញថា មាន១៦ភាគរយ ដែលសម្រេចសាលក្រមចុងក្រោយលើរឿង ក្តីអំពើហិង្សាលើស្ត្រីនិងកុមារ បើប្រៀបធៀបទៅ នឹងករណីឧក្រិដ្ឋកម្មមានដល់ទៅ ៧៥ភាគរយ។ ករណីនេះមានការកើនឡើងចំនួន៣២ភាគរយ នៅក្នុងឆ្នាំ២០១១ បន្ទាប់ពីការណែនាំដំបូង នៃទិន្នន័យមូលដ្ឋានត្រឹមត្រូវ[74]។
- ការដោះស្រាយតាមការផ្តល់ឱកាសសម្រាប់ការសងជំងឺចិត្ត គឺជាការទទួលសំណងដ៏ សំខាន់មួយសម្រាប់ការរំលោភសេពសន្ថវៈ ប៉ុន្តែការទទួលសំណងនេះគឺជាការបង្ក ឱកាសឱ្យជនល្មើសប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនេះម្តងទៀត ។
- ប្រព័ន្ធសុខាភិបាលមិនទាន់មានគោលការណ៍ណែនាំនៅឡើយ (ខ្វះក្រមសីលធម៌) សម្រាប់ការជួយគាំទ្រ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទោះជាយ៉ាងណាក៏ដោយ ក៏គោលការណ៍ណែនាំនេះនឹងដំណើរការរៀបចំបណ្តើរៗ។
- ពេទ្យជំនាញខ្វះចំណេះដឹងស្តីពីច្បាប់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ឱសថ ការរក្សា ភស្តុតាងតាមផ្លូវច្បាប់សម្រាប់ការកាត់ក្តី ។
- ការធ្វើកោសល្យវិច័យនៅតាមមន្ទីរពេទ្យនានាមានតម្លៃថ្លៃ ហើយអាចរកបាននៅ កម្រិតថ្នាក់រាជធានី ខេត្ត ប៉ុណ្ណោះ។

## ការផ្តល់ជូនសេវាសង្គម និងការគាំទ្រផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើហិង្សា លើស្ត្រី និងកុមារីនៅមិនទាន់មានលក្ខណៈជាប្រព័ន្ធ ហើយសេវាទាំងនោះនៅមិន ទាន់ទៅដល់ស្ត្រីទាំងអស់នោះនៅឡើយ

- ការយល់ដឹងអំពីបញ្ហារបស់ស្ត្រីងាយរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងកុមារី ឬ បញ្ហាប្រឈមនានាមួយចំនួនដែលទាក់ទងនឹងការទទួលបាននូវកិច្ចការពារ និង សេវាសង្គមមានការកើនឡើងជាងមុន ។

[74] East-West Management Institute. Facing the facts: How evidence-based programs improve gender based violence prosecutions in Cambodia. Phnom Penh: USAID, 2012.

- អ្នកជំនាញការជាច្រើនបានបញ្ជាក់ថា អ្នកធ្លាប់រងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងកុមារីត្រូវការសេវាជាច្រើន ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា សេវាទាំងនោះនៅមិនទាន់បានសមស្របនៅឡើយ។ នៅតំបន់ជនបទភាគច្រើនសេវាទាំងនោះនៅមិនទាន់បានទៅដល់ ហើយស្ត្រីទាំងអស់ក៏ពុំទាន់ទទួលបានសេវានោះដែរ ជាពិសេសស្ត្រីដែលងាយរងគ្រោះ។

- សេវាសហគមន៍តាមមូលដ្ឋាននៅមានកម្រិតនៅឡើយ។

- នៅប្រទេសកម្ពុជា មូលនិធិសម្រាប់វិស័យការងារសង្គម គឺនៅមានកម្រិត បច្ចុប្បន្ន ក្នុងចំណោមប្រជាពលរដ្ឋចំនួន១០០.០០០នាក់ ជាមធ្យមមានមន្ត្រីដែលធ្វើការផ្នែកសុខុមាលភាពសង្គមសាធារណៈចំនួន៤នាក់ប៉ុណ្ណោះ ។

- ស្ត្រីមួយចំនួនធំខ្វះការគាំទ្រផ្នែកច្បាប់ ឬអ្នកតំណាង[75] ។

- ការសហការមិនទាន់បានគ្រប់ជ្រុងជ្រោយរវាងអ្នកផ្តល់សេវា និងអ្នកសំខាន់ផ្សេងៗទៀត ស្តីពីកិច្ចការពារ និងយុទ្ធសាស្ត្រឆ្លើយតប[76]។

## កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់មានភាពខ្លាំងក្លាជាងមុន ប៉ុន្តែគួរតែបន្តការយកចិត្តទុកដាក់លើវិធានការទប់ស្កាត់បឋម និងការទប់ស្កាត់បន្ទាប់ (Primary and secondary prevention) ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី

- ចំណេះដឹងផ្នែកច្បាប់ មានសារៈសំខាន់ខ្លាំងណាស់ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់នោះទេ សម្រាប់ការផ្លាស់ប្តូរឥរិយាបថ។ កម្មវិធីដៃគូដើម្បីការទប់ស្កាត់នៅក្នុងឆ្នាំ២០១២ ឱ្យដឹងថា មានបុរស ៩៤ភាគរយ បានរាយការណ៍ថា ពួកគេមិនទាន់បានដឹងអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅឡើយទេ ១៦,៤ភាគរយនៃបុរសរាយការណ៍ថា ពួកគេនៅតែប្រព្រឹត្តអំពើហិង្សាផ្លូវកាយ ២០.៨ភាគរយ ប្រព្រឹត្តអំពើហិង្សាផ្លូវភេទ និង ៣២,៨ភាគរយ ប្រព្រឹត្តអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ឬទាំងពីរ។ ការសិក្សាថ្មីៗផ្សេងទៀតប្រហាក់ប្រហែលគ្នានេះដែរ បានឱ្យដឹងថា ទោះបីជាមានបុរស ៩២ភាគរយ និងស្ត្រី៩០ភាគរយ ដែលដឹងថាមានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះក៏ដោយ ប៉ុន្តែមាន

75 MoWA. Review of 1st National Action Plan to Prevent Violence Against Women. Phnom Penh: MoWA, 2012.

76 Ibid.

តែបុរស៦ភាគរយ និងស្ត្រី១០ភាគរយ ប៉ុណ្ណោះដែលយល់ដឹងថាស្ត្រីមានសិទ្ធិមិនទទួលរងនូវអំពើហិង្សា[77]។

- កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់បន្ទាប់ (secondary prevention) នៅមានកម្រិតនៅឡើយហើយអ្វីដែលសំខាន់នោះ គឺការធានាបាននូវការឆ្លើយតបរហ័សទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងកុមារី ដូចជាសេវាសង្គ្រោះបន្ទាន់ និងការថែទាំសុខភាពឱ្យបានសមស្រប ហើយសេវាទាំងនោះអាចទៅដល់អ្នករងគ្រោះដោយសារអំពើហិង្សាលើស្ត្រី និងកុមារីគ្រប់ៗគ្នា។

[77] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang. Why do some men use violence and how can we prevent it? Bangkok: UN Women Cambodia, 2013.

# អនុសាសន៍សម្រាប់គោលនយោបាយ

## ច្បាប់ និងគោលនយោបាយ

| *ពង្រឹងបរិកាសគោលនយោបាយឆ្ពោះទៅការពារការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី* | |
|---|---|
| • បញ្ចប់ការប៉ាន់ប្រមាណថវិកា រៀបចំនិងអនុវត្តសកម្មភាពជាអាទិភាពនៃផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ និង ផែនការសកម្មភាពជាតិ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស រត់ពន្ធ និងការធ្វើអាជីវកម្មផ្លូវភេទ។ | MoWA, MoI, Council of Ministers |
| • បញ្ចប់ការប៉ាន់ប្រមាណថវិកា ទៅលើសកម្មភាពជាអាទិភាពដែលឆ្លើយតបនឹងបញ្ហាបានរកឃើញដោយការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារ និងមនុស្សវ័យក្មេងនៅកម្ពុជា។ | MoH |
| • ធានាថាជនរងគ្រោះទទួលបានការធ្វើកោសល្យវិច័យមានលក្ខណៈសមរម្យ និងមិនគិតថ្លៃ ហើយបុគ្គលិកពេទ្យមានជំនាញច្បាស់លាស់ក្នុងការធ្វើកោលស្យវិច័យ។ លើកកម្ពស់សេវាការពាររោគដោយមានការពាររោគឆ្លងពីមេរោគអេដស៍ ការពិនិត្យបន្ទាន់ លើការឆ្លងមេរោគពាក់ព័ន្ធនឹងផ្លូវភេទនិងភាពគ្មានកូន និងសេវាសុខភាពបន្តពូជនានារួមទាំងការពិនិត្យសុខភាព និងការព្យាបាល[78]។ | MoSVY |
| • អនុវត្តច្បាប់ឱ្យបានទូលំទូលាយពាក់ព័ន្ធនឹងសមភាពយេនឌ័រដោយមានបញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រីទាំងការរើសអើងដោយផ្ទាល់ និងដោយប្រយោលស្របតាមមាត្រា១ នៃអនុសញ្ញាស៊ីដ ( សេចក្តីអង្កេតសន្និដ្ឋានទូទៅនៃអនុសញ្ញា CEDEW- CO 11 ) | MoH |

78 ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ ( 2nd NAPVAW)

| | |
|---|---|
| • លើកកម្ពស់សីលធម៌នៃប្រព័ន្ធផ្សព្វផ្សាយ សម្រាប់រាយការណ៍អំពីអំពើហិង្សាលើស្ត្រី និងគោលការណ៍ណែនាំជាស្តង់ដារ គ្រប់គ្រងដោយក្រុមប្រឹក្សាប្រព័ន្ធ ផ្សព្វផ្សាយ។ | MoH |
| • បង្កើតគោលនយោបាយនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យាដើម្បី រួមចំណែកបង្កើនការយល់ដឹងនិងទប់ស្កាត់អំពើហិង្សាលើស្ត្រី។ | MOF |
| • កែសម្រួលប្រព័ន្ធប្រតិបត្តិការចំណាយ និងក្រមសីលធម៌សម្រាប់គោលនយោបាយ និងសុខដុមនីយកម្មជាមួយនឹងក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ រួមទាំងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR 1325[79])។ | MoI |
| • អនុវត្តសេចក្តីណែនាំថ្នាក់ជាតិស្តីពីការប្រឆាំងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារអនុវត្តនៅក្នុងវិស័យសុខាភិបាល[80]។ | MoH |
| *បន្តពង្រឹងសុខដុមនីយកម្មក្នុងក្របខណ្ឌច្បាប់ ស្តីពីអំពើហិង្សាលើស្ត្រី និងកុមារី* | |
| • បញ្ចប់ការប៉ាន់ប្រមាណនៃភាពជោគជ័យ និងបញ្ហាប្រឈមនៅក្នុងប្រព័ន្ធច្បាប់ឆ្លើយតបនឹងលទ្ធផលនៅក្នុងអនុសាសន៍ ដើម្បីកែលម្អច្បាប់គោលនយោបាយ ស្តីពីអំពើហិង្សាលើស្ត្រីនិងកុមារី រួមទាំងច្បាប់ការងារ និងគោលការណ៍ណែនាំស្តីពីការបៀតបៀនកេរ្តិ៍ភេទ ដោយបញ្ជាក់ពីភាពជាអាណាព្យាបាលសម្រាប់អនីតិជន។<br>o ពិនិត្យឡើងវិញលើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ(សំណង និងវិធានការរដ្ឋបាល)។<br>o ពិនិត្យឡើងវិញលើច្បាប់ស្តីពីការ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ[81]។ | MoJ, MoI, MoSVY, MoWA |

79 ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ (2nd NAPVAW)
80 ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ (2nd NAPVAW)
81 CEDAW 27.

| | |
|---|---|
| o ពិនិត្យឡើងវិញលើក្រមនីតិវិធីរដ្ឋប្បវេណី ជាពិសេសទាក់ទងទៅនឹងអំណាចរបស់ឪពុកម្ដាយដែលបញ្ជាទៅលើកូន។ ពិនិត្យឡើងវិញលើគោលការណ៍ណែនាំ ស្ដីពីគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។<br>o បញ្ជាក់ពីអត្ថន័យនៃមណ្ឌលកម្សាន្តរបស់មនុស្សពេញវ័យ[82]។<br>o ពិនិត្យឡើងវិញលើច្បាប់ស្ដីពី ការងារ និងសេចក្ដីណែនាំស្ដីពីការបៀតបៀនកេរ្ដិ៍ភេទ។ | |
| • រៀបចំនិងពង្រឹងគោលការណ៍ជាក់លាក់ក្នុងការអនុវត្តនៅថ្នាក់ជាតិលើការបង្កើតប្រព័ន្ធដ៏មានប្រសិទ្ធភាព ដើម្បីកំណត់ពីការរាយការណ៍ និងបញ្ជូនករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសក្រុមស្ត្រីងាយរងគ្រោះ[83]។ | MoWA |
| • អនុម័តលើក្របខណ្ឌសម្រាប់អាជ្ញាកណ្ដាល ឬជម្រើសនៃការដោះស្រាយជម្លោះដ៏ល្អបំផុតសម្រាប់ជួយក្រុមងាយរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងក្មេងស្រី[84]។ | MoJ |
| *ធានាថាជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទទួលបានសេវាពី តុលាការប្រកបដោយប្រសិទ្ធភាព* | |
| • ផ្ដល់វគ្គបណ្ដុះបណ្ដាលដល់មន្ត្រីអនុវត្តច្បាប់ និងតុលាការ ដើម្បីធានាថាករណីអំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ អនុវត្តមានប្រសិទ្ធភាព និងមិនផ្ដោតលើប្រព័ន្ធអាជ្ញាកណ្ដាល[85] ។ | MoWA |
| • អភិវឌ្ឍប្រព័ន្ធជំនួយផ្នែកច្បាប់សម្រាប់ផ្ដល់សេវាផ្លូវច្បាប់ដោយមិនគិតថ្លៃ ដល់ស្ត្រី និងបង្កើនថវិកាដល់សមាគមក្លឹបកម្សាន្ត និងផ្ដល់សេវាប្រឹក្សាយោបល់ ដោយមិនគិតថ្លៃ ដើម្បីធានាប្រសិទ្ធភាពនៃការទទួលបានយុត្តិធម៌[86] ។ | MoJ |

82 2nd NAPVAW; 2nd NPA STSLS.
83 2nd NAPVAW; 2nd NPA STSLS.
84 CEDAW; 2nd NAPVAW.
85 CEDAW 21a; 2nd NAPVAW.
86 CEDAW 13b; 2nd NAPVAW; 2nd NPA STSLS.

| | |
|---|---|
| • លើកទឹកចិត្តស្ត្រី និងក្មេងស្រីឱ្យដាក់ពាក្យបណ្តឹងជាផ្លូវការលើករណីអំពើហិង្សាមកលើខ្លួនតាមរយៈការបង្កើនចំណេះដឹងអំពីបទឧក្រិដ្ឋរបស់ជនល្មើស[87] ។ | MoWA, MoI, MoJ |
| • ផ្តល់គោលការណ៍ណែនាំច្បាស់លាស់ទៅមន្ត្រីរាជរដ្ឋាភិបាល ដើម្បីពង្រឹងការអនុវត្តច្បាប់ ជាជាងការទូទាត់សំណងជាប្រាក់។ | MoI |
| • ពង្រឹងការអនុវត្តច្បាប់សម្រាប់ជនល្មើសប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងកុមាររួមទាំងអ្នកជួញដូរមនុស្ស[88] ។ | MoJ |
| • ធានាឱ្យមានវិធានការការពារដាក់លាក់សម្រាប់ស្ត្រីនៅក្នុងប្រព័ន្ធតុលាការរួមទាំងភាពប្រឈមមុខដាក់គ្នាជាមួយជនល្មើស និងវិធានការការពារសាក្សី ។ | MoJ, |
| • លើកកម្ពស់ការប្រើដីកាការពារ និងការរក្សាឯកសារស្តីពីចំនួនដីកាការពារ [89] ។ | MoI |
| • ពង្រឹងការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការរំលោភសេពសន្ថវៈ [90] ។ | MoI |
| • ស៊ើបអង្កេត និងផ្តន្ទាទោសអំពើពុករលួយក្នុងការងាររដ្ឋបាលដែលទាក់ទងនឹងច្បាប់ និងដាក់ទោសជនល្មើសតាមកំហុសរបស់ខ្លួន [91] ។ | MoJ, MoI |
| • ស៊ើបអង្កេត និង ផ្តន្ទាទោសករណីបំពានផ្លូវភេទរបស់អ្នកអនុវត្តច្បាប់ដែលបានប្រព្រឹត្តលើស្ត្រីបំរើសេវាផ្លូវភេទ [92] ។ | MoJ, MoI |

87 CEDAW 21b.
88 CEDAW 25c; 2nd NPA STSLS.
88 CEDAW 21d; 2nd NAPVAW.
89 CEDAW 25a; 2nd NPA STSLS.
90 CEDAW 13c.
91 CEDAW 27.
92 CEDAW 19a; 2nd NAPVAW.

| | |
|---|---|
| • បង្កើតតុលាការអនីតិជន ដោយមាននគរបាលជំនាញ ក្រឡាបញ្ជី ព្រះរាជអាជ្ញា ចៅក្រម និងបុគ្គលិកសង្គមកិច្ច ក្នុងករណីអនីតិជន ដោយប្រើប្រាស់ដំណើរការងាយស្រួលសម្រាប់កុមារ។ | MoJ |
| *ការលើកកម្ពស់កិច្ចប្រឹងប្រែងទប់ស្កាត់អំពើហិង្សាប្រឆាំងស្ត្រីនិងកុមារី* | |
| • រៀបចំនិងអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់ដែលមានការចូលរួមគ្រប់វិស័យ ដោយផ្តោតលើតួអង្គសំខាន់ៗ ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត ឥរិយាបថ អាកប្បកិរិយា ជំនឿ ការអនុវត្តន៍ ដែលប៉ះពាល់លើការផ្តល់ភាពអង់អាចដល់ស្ត្រី និងលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារី[93] ជាពិសេសស្ត្រីជនជាតិដើមភាគតិច និងជនពិការ[94] ។ | MoEYS, MoWA |
| • កំណត់សកម្មភាពអប់រំដល់មនុស្សពេញវ័យ និងយុវវ័យដែលប្រឈមនឹងបទដ្ឋានសង្គម ការប្រព្រឹត្តិ ព្រមទាំងវិសមភាពនៃទំនាក់ទំនងយេនឌ័រ ការរើសអើង និងអតុល្យភាពអំណាច[95] ។ | MoWA, MoEYS |
| • បង្កើនសមត្ថភាពរបស់មនុស្សក្នុងការកំណត់អំពើហិង្សា លើកកម្ពស់ការយល់ដឹងស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេសស្ត្រីដែលងាយរងគ្រោះ និងនៅទីជនបទ[96] ។ | MoEYS, MoWA, MoSVY |
| • លើកកម្ពស់កម្មវិធីសម្រាប់យុទ្ធសាស្ត្រទំនាក់ទំនងអហិង្សា និងជំនាញដោះស្រាយជម្លោះរវាងប្តីនិងប្រពន្ធ និងក្នុងក្រុមគ្រួសារ ហើយនិងទម្រង់អហិង្សា សម្រាប់កុមារ ក្នុងចំណោមឪពុកម្តាយ និងអ្នកថែទាំ[97] ។ | MoWA, MoSVY |
| • លើកកម្ពស់កម្មវិធីដែលលើកទឹកចិត្តដល់ជនល្មើសឱ្យឈប់ប្រើអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដើម្បីបញ្ឈប់អំពើហិង្សា[98] ។ | MoWA, MoJ |

93 CEDAW 19a; 2nd NAPVAW.
94 2nd NAPVAW.
95 CEDAW 21c; 2nd NAPVAW.
96 2nd NAPVAW.
97 2nd NAPVAW.
98 2nd NAPVAW.

| | |
|---|---|
| • ពង្រឹងយុទ្ធសាស្ត្រលើកកម្ពស់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី[99] ។ | MoLVT, MoWA |
| • លើកកម្ពស់យុទ្ធសាស្ត្រសហគមន៍សម្រាប់សុវត្ថិភាពស្ត្រីនិងកុមារីក្នុងទីសាធារណៈ និងសាលារៀន[100] ។ | MoI, MoWA |
| • លើកកម្ពស់ភាពមិនអាចអត់ឱនចំពោះការបៀតបៀនកេរ្តិ៍ភេទនៅកន្លែងធ្វើការ[101] ។ | MoLVT |
| **កិច្ចការពារផ្លូវច្បាប់ និងសេវាពហុវិស័យ** | |
| *ធ្វើឱ្យឱ្យប្រសើរឡើងនូវការសម្របសម្រួល បរិមាណ គុណភាពនៃសេវាពហុវិស័យ* | |
| • ពង្រឹងក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនូវសេវាកម្ម ដើម្បីរៀបចំយន្តការឆ្លើយតបដែលមានការសម្របសម្រួលពហុវិស័យ ដែលអាច ឱ្យស្ថាប័នរាជរដ្ឋាភិបាល អ្នកផ្តល់សេវានិងសង្គមស៊ីវិល ធ្វើការសម្របសម្រួល និងផ្តល់កិច្ចអន្តរាគមន៍ដែលត្រូវបញ្ចូលក្នុងមជ្ឈមណ្ឌលសម្រាប់ជនរងគ្រោះ ចំពោះការទប់ស្កាត់អំពើហិង្សាលើ ស្ត្រី និង ក្មេងស្រី[102] ។ | MoWA and other partners |
| • លើកកម្ពស់កិច្ចសម្របសម្រួលដែលត្រូវបានបង្កើនរវាងនគរបាលជាតិ អាជ្ញាធរមូលដ្ឋាន អ្នកទទួលបន្ទុកកិច្ចការនារីឃុំ សេវាសុខភាព អ្នកជំនាញ ច្បាប់ និងភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី បុគ្គលិកសង្គម របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ គាំទ្រដទៃទៀត ដើម្បីផ្តល់កិច្ចការពារជាអតិប្បរិមា និងការថែទាំសម្រាប់ ជនរងគ្រោះ ក៏ដូចជាដើម្បីលើកកម្ពស់ការកាត់ទោសជនល្មើស[103] ។ | MoWA, MoI, CNP, MoSVY, MoH |

[99] 2nd NAPVAW.
[100] 2nd NAPVAW.
[101] 2nd NAPVAW; 2nd NPA STSLS.
[102] 2nd NAPVAW; 2nd STSLS.
[103] 2nd NAPVAW.

| | |
|---|---|
| • រៀបចំកម្រិតស្តង់ដាអប្បរិមានៃសេវាសម្រាប់សេវាសង្គមផ្សេងៗ ដែលបំពេញគម្លាត និងធ្វើសុខដុមនីយកម្មជាមួយស្តង់ដាដែលមាន និងងាយស្រួលសម្រាប់កុមារ ហើយត្រូវអនុវត្តស្តង់ដារដែលមាននោះ ជាគោលការណ៍ណែនាំ និងប្រឹក្សាបឋមសម្រាប់ការណែនាំ។ | MoWA, |
| • អនុវត្តប្រព័ន្ធស្តង់ដាដែលមានស្រាប់ដោយផ្អែកលើគោលការណ៍ណែនាំស្តីពីការប្រឹក្សាយោបល់ និងការបញ្ជូន[104] ។ | MoSVY |
| • ពង្រីកគំរូសេវាដែលផ្អែកលើភស្តុតាង ដើម្បីធានាថា ជនរងគ្រោះនៃអំពើហិង្សា អាចទទួលបានសេវាដោយផ្អែកលើតម្រូវការរបស់បុគ្គលម្នាក់ៗ ដោយរាប់បញ្ចូលទាំងជម្រើសការថែទាំនៅសហគមន៍ និងយុទ្ធសាស្ត្រ ដែលដោះស្រាយតម្រូវការរបស់ស្ត្រីគ្រប់រូបដោយរាប់បញ្ចូលទាំងស្ត្រី និងកុមារីងាយរងគ្រោះពីអំពើហិង្សាផងដែរ[105] ។ | MoWA, MoSVY |
| • បង្កើនចំនួនអ្នកបម្រើការងារសង្គមកិច្ចនិងធ្វើឱ្យប្រសើរឡើងនូវវគ្គបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាសង្គមនៅក្នុងប្រព័ន្ធមូលនិធិសង្គមនិងកុមារ[106]។ | MoSVY |
| • លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ដោយរាប់បញ្ចូលទាំងបណ្តាញសង្គមក្នុងការចែករំលែកការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើ ហិង្សាលើស្ត្រីនិងកម្មេងស្រី[107] ។ | MoWA, MoSVY, MoI |
| • បង្កើនចំនួននគរបាលជាស្ត្រី មេធាវី ចៅក្រម ព្រះរាជអាជ្ញានិងវេជ្ជបណ្ឌិតជំនាញកោសល្យវិច្ច័យ[108] ។ | MoI, MoH MoWA |

104 2nd NAPVAW; 2nd STSLS.
105 2nd NAPVAW; 2nd NPA STSLS.
106 2nd NAPVAW.
107 2nd NAPVAW.
108 2nd NAPVAW.

| | |
|---|---|
| *លើកកម្ពស់ការផ្តល់សេវា និងសំណងសម្រាប់ស្ត្រី និងកុមារី ដែលងាយរងគ្រោះ ឬអ្នកដែលមានបញ្ហាប្រឈមនឹងការទទួលបានយុត្តិធម៌* | |
| • អ្នកផ្តល់សេវាទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារីគួរដោះស្រាយឧបសគ្គបណ្តាលមកពីហេដ្ឋារចនាសម្ព័ន្ធ ទំនាក់ទំនង ឬឧបសគ្គផ្សេងៗទៀត ដើម្បីផ្តល់សេវា ដល់ស្ត្រីពិការ[109] ។ | MoWA, MoSVY |
| • ផ្តល់សំណងដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម[110]។ | MoWA, MoSVY, MoH |
| • ធានាការគាំទ្រផ្នែកផ្លូវចិត្ត និងសង្គមឱ្យបានគ្រប់គ្រាន់ [111]។ | |
| • លើកកម្ពស់សេវាដែលឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ស្ត្រី និងក្មេងស្រី ដែលងាយរងគ្រោះដោយអំពើហិង្សា[112]។ | MoWA, MoSVY, MoI |
| *បង្កើនសមត្ថភាពអ្នកពាក់ព័ន្ធសំខាន់ៗដែលផ្តល់សេវានិងការឆ្លើយតប* | |
| • លើកកម្ពស់កិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាព ស្តីពីសក្តានុពលនៃការទប់ស្កាត់អំពើហិង្សា ច្បាប់ និងគោលនយោបាយ និង ការអនុវត្តន៍ផ្អែកលើភស្តុតាងជាមូលដ្ឋានសម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ ដោយរាប់បញ្ចូលទាំងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ នគរបាលជាតិកម្ពុជា សេវាសុខភាព វេជ្ជបណ្ឌិត ចៅក្រម ព្រះរាអាជ្ញា ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី អ្នកផ្តល់សេវា និងអ្នកដទៃទៀត[113]។ | MoWA, MoSVY, MoI, CNP, MoH |

109 CEDAW15; 2nd NAPVAW.
110 2nd NAPVAW; 2nd NPA STSLS.
111 2nd NAPVAW.
112 2nd NAPVAW; 2nd NPA STSLS.
113 2nd NPA STSLS; 2nd NAPVAW.

| | |
|---|---|
| • បង្កើនការអប់រំកិច្ចការសង្គម និងវគ្គបណ្ដុះបណ្ដាលសម្រាប់អ្នកផ្ដល់សេវា[114]។ | |
| • ផ្ដល់ការអប់រំផ្នែកច្បាប់ដល់វេជ្ជបណ្ឌិត គ្រូពេទ្យ ឬអ្នកផ្ដល់សេវាសុខាភិបាល ដើម្បីអាចទទួលខុសត្រូវលើការធ្វើកោសល្យវិច័យ។ | MoH, MoJ |
| *ការសិក្សាស្រាវជ្រាវ ការត្រួតពិនិត្យ និងវាយតម្លៃ* | |
| • រៀបចំការអង្កេតជាមូលដ្ឋាន ដើម្បីកំណត់គម្លាតក្នុងចំណោមអ្នកផ្ដល់សេវា ទាំងអស់នៅថ្នាក់ក្រោមជាតិ (រួមទាំងអ្នកធ្វើការងាររាជការ និងមិនមែនរាជការ) ដែលរាំងស្ទះប្រព័ន្ធបញ្ជូន ពេលវេលានៃការឆ្លើយតបពីអ្នកផ្ដល់សេវានិងចំនួននៃការប៉ុនប៉ងស្វែងរកជំនួយរបស់ស្ត្រីអាចនឹងថយចុះ ប្រកបដោយប្រសិទ្ធភាព។ | MoWA,<br>MoSVY,<br>MoI, MoH,<br>MoJ |
| • អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងប្រព័ន្ធតាមដានត្រួតពិនិត្យ និងភ្ជាប់ទិន្នន័យពីថ្នាក់ក្រោមជាតិ មកអ្នកធ្វើគោលនយោបាយនៅថ្នាក់ជាតិ [115]។ | |
| • សិក្សាស្រាវជ្រាវអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្តន៍ជាក់ស្តែងទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី[116] ស្តីពីៈ<br>o ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មស្ត្រី និងក្មេងស្រី<br>o ដីការការពារ និងយុទ្ធសាស្ត្រឆ្លើយតប<br>o មូលហេតុ កត្តាផ្សេងៗ ផលប៉ះពាល់ទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី<br>o ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងការកើនឡើងនូវអំពើហិង្សា ។ | MoWA |
| • បញ្ចប់ការធ្វើអង្កេតស្តីពីប្រេវ៉ាឡង់អំពើហិង្សាលើស្ត្រីនិងក្មងស្រីរបស់អង្គការសុខភាពពិភពលោក។ | MoWA |

114 2nd NAPVAW.
115 CEDAW 21d; 2nd NAPVAW; 2nd NPA STSLS.
116 CEDAW 21d; 2nd NAPVAW; 2nd NPA STSLS.

| | |
|---|---|
| • ធ្វើការអង្កេតតាមដានថ្មីរបស់ក្រសួងកិច្ចការនារី លើអាកប្បកិរិយា និងផ្នត់ គំនិតដែលទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី | MoWA |
| • លើកកម្ពស់ការប្រមូលទិន្នន័យបែងចែកតាមភេទនៅក្នុងក្រសួងពាក់ព័ន្ធទាំងអស់ទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ | All Ministries |

# សេចក្តីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការរៀប ចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ក្រសួងកិច្ចការនារី លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថេ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋានសមភាពយេនឌ័រ លោកស្រី តែ វួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិកផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមានការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមានលោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួលទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្តល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នកជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយពិនិត្យ ឡើងវិញលើសេចក្តីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្តល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៧៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ ស៊ី ដេហ្វីន រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងលោកជំទាវ ទេស ច័ន្ទសារឿន អនុរដ្ឋលេខាធិការ

ក្រសួង កិច្ចការនារី ចងក្រងសេចក្តីព្រាងដោយលោកស្រី Robin Mauney ក្រោមការឧបត្ថម្ភពី Australian Aid/DFAT និងផ្តល់ធាតុចូលដោយ លោកជំទាវ ខៀវ សិរីវុឌ្ឍា អគ្គនាយិកាក្រសួងកិច្ចការនារី លោកស្រី សាខឿន សារ៉ាតឌី អគ្គនាយិការង លោកស្រី កែត ម៉ារឌី ប្រធាននាយកដ្ឋានការពារ ផ្លូវច្បាប់ និងគម្រោង Access to Justice for Women ។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉េល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh